សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ

និងវិទ្យាសាស្ត្រសេដ្ឋកិច្ច


## សារណាបញ្ចប់ការសិក្សា

# ប្រសិទ្ធភាពសេដ្ឋកិច្ចនៃផលិតកម្មស្ករត្នោតកំពង់ស្ពឺ ក្រោមស្លាកសញ្ញាទំនិញសម្គាល់ភូមិសាស្ត្រ

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧


| តាក់តែងឡើងដោយ | | សាស្ត្រាចារ្យណែនាំ | |
| --- | --- | --- | --- |
| និស្សិតឈ្មោះ | **តែ វណ្ណាច័ន្ទ** | បណ្ឌិត | **ឈុន ពហុ** |
| | **ឈុន ឈៀងហៃ** | | |


| | | | |
| --- | --- | --- | --- |
| ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច | | ឆ្នាំចូលសិក្សា | ២០១៣ |
| ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ | ជំនាន់ទី ១៦ | ឆ្នាំសរសេរសារណា | ២០១៧ |

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំ ឆៃ វណ្ណច័ន្ទ និង ឈុន ឈៀងហៃ ដែលជានិស្សិតបរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ លោកឪពុក អ្នកម្ដាយ និងញាតិសន្ដានទាំងអស់ ដែលបានជួយថែរក្សាបីបាច់ផ្គត់ផ្គង់ទំនុកបម្រុងទាំងកម្លាំងកាយ កម្លាំងចិត្ត និងអ្វីៗគ្រប់បែបយ៉ាងដែលពួកយើងខ្ញុំត្រូវការ។ ជាពិសេសលោកឪពុក និងអ្នកម្ដាយដែលបានផ្ដល់កំណើតដល់ពួកយើងខ្ញុំ និងបានលះបង់សព្វគ្រប់បែបយ៉ាងក្នុងការផ្គត់ផ្គង់ដល់ការរស់នៅ និងការសិក្សារហូតដល់សព្វថ្ងៃ ហើយពួកគាត់មិនដែលរអ៊ូរទាំបន្តិចណាឡើយ ទោះបីអ្នកទាំងពីរស្ថិតក្នុងស្ថានភាពនឿយហត់ និងលំបាកយ៉ាងណាក៏ដោយ។ ម្យ៉ាងវិញទៀតអ្នកមានគុណទាំងពីរបានផ្ដល់នូវការអប់រំទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ ដើម្បីឲ្យកូនៗទទួលបានជោគជ័យក្នុងជីវិត និងចង់ឃើញពួកយើងខ្ញុំក្លាយជាមនុស្សមានកិត្តិយសក្នុងសង្គម។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ពហុ** ជាគ្រូបង្គោលដែលបានជួយត្រួតពិនិត្យ ពន្យល់ ណែនាំ ចង្អុលបង្ហាញផ្លូវក្នុងការធ្វើសារណានេះអោយបានប្រព្រឹត្តទៅដល់ទីបញ្ចប់យ៉ាងរលូនប្រកបដោយភាពជោគជ័យ។

សូមថ្លែងអំណរគុណដល់មិត្តភក្ដិរបស់ពួកយើងខ្ញុំទាំងអស់ ដែលតែងតែជួយក្រើនរំលឹក និងផ្ដល់ជាកម្លាំងចិត្ត រហូតសម្រេចបានជោគជ័យក្នុងការសិក្សាកន្លងមក។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមអរគុណយ៉ាងក្រៃលែងដល់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច គ្រប់រូប ចាប់តាំងពីថ្នាក់ឆ្នាំមូលដ្ឋានរហូតដល់ឆ្នាំទី៤ ដែលលោកបានខិតខំយកចិត្តទុកដាក់ក្នុងការបង្រៀន និងពន្យល់ណែនាំ ដើម្បីផ្ទេរចំណេះដឹង បទពិសោធន៍ល្អៗដល់និស្សិតគ្រប់រូប។

# អារម្ភកថា

សូមស្វាគមន៍មិត្តៗនិស្សិត ប្រិយមិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ និងអ្នកដែលចង់ស្វែងយល់នូវប្រធានបទសារណាដែលមានចំណងជើងថា “ **ប្រសិទ្ធភាពសេដ្ឋកិច្ចនៃផលិតកម្មស្ករត្នោតក្រោមស្លាកសញ្ញាទំនិញសម្គាល់ភូមិសាស្ត្រ** ”។ យើងខ្ញុំមានសេចក្ដីសប្បាយរីករាយយ៉ាងក្រៃលែងដែលទទួលបានការណែនាំ ពន្យល់បង្ហាញ ត្រួតពិនិត្យ និងកែលំអ ពីលោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ពហុ** លើប្រធានបទសារណាបញ្ចប់ការសិក្សាខាងលើនេះ។

រុក្ខជាតិត្នោត គឺជាសម្បត្តិធម្មជាតិមួយប្រភេទដែលត្រូវបានចាត់ទុកជាគ្រឿងសម្គាល់អត្តសញ្ញាណជាតិខ្មែរ ស្របតាមព្រះរាជក្រឹត្យចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីនាមកត្តានៃសត្វ និងរុក្ខជាតិដែលជានិមិត្តរូបតំណាងឲ្យព្រះរាជាណាចក្រកម្ពុជា។ ហេតុនេះពួកយើងខ្ញុំ និងលោកសាស្ត្រាចារ្យណែនាំ បានសម្រេចចិត្តជ្រើសយកប្រធានខាងលើនេះមកធ្វើការស្រាវជ្រាវ និងបន្សល់ទុកជាឯកសារ ក្នុងន័យផ្សព្វផ្សាយបន្ថែមទៀតអំពីគុណប្រយោជន៍ និងគុណតម្លៃនៃរុក្ខជាតិត្នោតក្នុងជីវភាពរបស់ប្រជាជនខ្មែរ ដល់អ្នកសិក្សាដ៏ទៃទៀតដើម្បីបន្តចូលរួមទាំងអស់គ្នាក្នុងការថែរក្សា និងអភិរក្សរុក្ខជាតិប្រភេទនេះឲ្យបានគង់វង្សជាយូរអង្វែងតរៀងទៅ។

ទន្ទឹមនឹងនេះយើងខ្ញុំសង្ឃឹមថា កិច្ចការស្រាវជ្រាវមួយនេះ នឹងអាចរួមចំណែកដល់ប្អូនៗនិស្សិតជំនាន់ក្រោយៗដែលមានការចាប់អារម្មណ៍លើប្រធានបទខាងលើនេះ ទុកជាទុនសម្រាប់ធ្វើការស្រាវជ្រាវ និងអភិវឌ្ឍន៍បន្ថែមទៀតនាពេលអនាគត។ ទោះជាយ៉ាងណាអាស្រ័យដោយចំណេះដឹងមានកម្រិត និងកង្វះខាតបទពិសោធន៍ក្នុងការស្រាវជ្រាវ យើងខ្ញុំជឿជាក់ថាប្រាកដជាមានកំហុស និងចំណុចខ្វះខាតជាមិនខាន។ ហេតុនេះយើងខ្ញុំនឹងរង់ចាំទទួលនូវរាល់ការរិះគន់ពីសំណាក់មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ មិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយ រាល់កំហុសឆ្គងទាំងឡាយដែលកើតឡើងដោយអចេតនាដើម្បីជួយកែលំអសៀវភៅនេះកាន់តែប្រសើរឡើង។

ជាចុងក្រោយ ក្រុមយើងខ្ញុំសូមជូនពរដល់ មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ និងមិត្តនិស្សិតទាំងអស់ ទទួលបាននូវពរទាំងឡាយបួនប្រការ សម្បត្តិបី អរិយទ្រព្យប្រាំពីរ និងមានសេចក្តីសុខសំណាងល្អគ្រប់ពេលវេលា។

# មាតិកា

## សេចក្តីផ្តើម

១.លំនាំបញ្ហា ........ ១
២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១
៣. គោលបំណងនៃការស្រាវជ្រាវ ........ ២
៤. ទំហំ និងដែនកំណត់ ........ ២
៥. វិធីសាស្ត្រស្រាវជ្រាវ ........ ២
៥.១ វិធីសាស្ត្រប្រមូលទិន្នន័យ ........ ២
៦.សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
៧.រចនាសម្ព័ន្ធស្រាវជ្រាវ ........ ៣

## ជំពូកទី ១

## រំលឹកទ្រឹស្តី និងសំយោគឯកសារពាក់ព័ន្ធ

១.១ ប្រវត្តិនៃដើមកំណើតរុក្ខជាតិត្នោតនៅលើពិភពលោក ........ ៥
១.២ រុក្ខជាតិត្នោតនៅកម្ពុជា ........ ៥
១.២.១ ដើមកំណើតរុក្ខជាតិត្នោតនៅកម្ពុជា ........ ៥
១.២.២ ប្រភេទពូជនៃរុក្ខជាតិត្នោត ........ ៦
១.២.៣ លក្ខណៈជីវសាស្ត្ររបស់រុក្ខជាតិត្នោត ........ ៧
១.២.៤ អត្ថប្រយោជន៍របស់រុក្ខជាតិត្នោត ........ ៨
១.៣ សហាគមន៍កសិកម្ម ........ ៨
១.៣.១ និយមន័យនៃសហាគមន៍កសិកម្ម ........ ៨
១.៣.២ គោលនយោបាយគាំទ្ររបស់រាជរដ្ឋាភិបាលចំពោះសហាគមន៍កសិកម្ម ........ ៩
១.៤ សេដ្ឋកិច្ចនៅជនបទ ........ ១០
១.៥ ច្បាប់តម្រូវការ និង ផ្គត់ផ្គង់ ........ ១១
១.៥.១ ច្បាប់តម្រូវការ ........ ១១

១.៥.២ ច្បាប់ផ្គត់ផ្គង់ ........ ១១
១.៦ ការវិភាគ SWOT ( ស្វូត ) ........ ១១
១.៧ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃកត្តាផលិតកម្ម ........ ១២

## ជំពូកទី ២

## ស្ថានភាពទូទៅនៃសហគមន៍អភិវឌ្ឍន៍កសិកម្មត្នោតកំពង់ស្ពឺ

២.១ ស្ថានភាពទូទៅនៃតំបន់សិក្សា ........ ១៦
២.១.១ ទីតាំងភូមិសាស្ត្រនៃឃុំភ្នំតូច ........ ១៦
២.១.២ ស្ថានភាពសេដ្ឋកិច្ចប្រជាជនក្នុងឃុំភ្នំតូច ........ ១៦
២.១.៣ ស្ថានភាពសង្គមកិច្ចក្នុងឃុំភ្នំតូច ........ ១៦
២.១.៤. ស្ថានភាពពលកម្មនៅក្នុងគ្រួសារផលិតករដែលបានចូលរួមក្នុងផលិតកម្ម ........ ១៧
២.១.៥ ប្រភពដើមត្នោតរបស់ផលិតករ ........ ១៧
២.២ សហគមន៍អភិវឌ្ឍន៍កសិកម្មស្ករត្នោតកំពង់ស្ពឺ (ស.អ.ត.ក) ........ ១៨
២.២.១ រចនាសម្ព័ន្ធគ្រប់គ្រង ........ ១៨
២.២.២ តួនាទី និងភារកិច្ចរបស់សហគមន៍ ........ ១៩
២.២.៣ តំបន់ប្រត្តិបត្តិការរបស់សហគមន៍ ........ ១៩
២.២.៤ ធនធានហិរញ្ញវត្ថុ ........ ១៩
២.៣.ខ្សែចង្វាក់ផលិតកម្មស្ករត្នោតកំពង់ស្ពឺ ........ ២០
២.៣.១ តំបន់ភូមិសាស្ត្រ និងភស្តុតាងបញ្ជាក់ពីប្រភព ........ ២០
២.៣.២ ខួបនៃផលិតកម្មស្ករត្នោតកំពង់ស្ពឺ ........ ២០
២.៣.៣ ប្រភេទស្ករ ........ ២១
២.៣.៤ បច្ចេកទេសផលិតកម្ម ........ ២២
២.៣.៤.១ ដំណើរការនៃការប្រមូលផលទឹកត្នោត ........ ២២
២.៣.៤.២ ការកៀប និងចិតផ្កា ........ ២៣
២.៣.៤.៣ ការស្រុះ ឬអប់បំពង់ ........ ២៤

២.៣.៤.៤ ការដាក់ពពេល ........ ២៥

២.៣.៤.៥ ការរម្ងាស់ទឹកត្នោត ........ ២៥

២.៣.៤.៦ របៀបផលិតស្ករសាច់ ........ ២៦

២.៣.៤.៧ របៀបផលិតស្ករម្សៅ ........ ២៧

២.៣.៤.៨ របៀបផលិតស្ករផែន ........ ២៨

២.៣.៤.៩ ការទុកដាក់ ( ស្តុកស្ករ ) ........ ២៩

២.៣.៤.១០ ការវេចខ្ចប់ស្ករត្នោតកំពង់ស្ពឺ ........ ២៩

២.៤ ស្ថានភាពទីផ្សារ និងការចុះបញ្ជីស្ករត្នោតកំពង់ស្ពឺជាទំនិញសម្គាល់ភូមិសាស្ត្រ ........ ៣២

២.៤.១ ការចុះបញ្ជីស្ករត្នោតកំពង់ស្ពឺជាទំនិញសម្គាល់ភូមិសាស្ត្រ ........ ៣២

២.៤.២ ស្ថានភាពទីផ្សារមុនពេលចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ........ ៣២

២.៤.៣ ស្ថានភាពទីផ្សារក្រោយពេលចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ........ ៣៣

២.៥ ប្រត្តិបត្តិការទីផ្សារស្ករត្នោតកំពង់ស្ពឺរបស់ ស.អ.ត.ក ........ ៣៤

២.៥.១ បណ្តាញទីផ្សារស្ករត្នោតកំពង់ស្ពឺ ........ ៣៤

២.៥.២ ទំហំនៃការធ្វើពាណិជ្ជកម្មស្ករត្នោតកំពង់ស្ពឺ ........ ៣៥

២.៥.៣ ការកំណត់ថ្លៃទីផ្សារ ........ ៣៧

២.៦. ការធ្វើអនាម័យ ........ ៣៨

២.៧ ការត្រួតពិនិត្យគុណភាព ........ ៣៨

២.៨ គណនេយ្យ និងការស្វែងរកទីកដាន ........ ៣៨

២.៩ ការដាក់ទណ្ឌកម្ម ........ ៣៩

## ជំពូកទី ៣

## ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

៣.១ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃផលិតកម្មស្ករត្នោតកំពង់ស្ពឺក្នុងឃុំភ្នំតូច(១វដ្តផលិតកម្ម) ........ ៤០

៣.១.១ ចំណាយសរុបជាមធ្យម របស់ផលិតករក្នុងការផលិតស្ករម្សៅ GI ........ ៤០

៣.១.២ ចំណូលសរុបជាមធ្យម របស់ផលិតករក្នុងការផលិតស្ករត្នោតម្សៅ GI ........ ៤៣

៣.១.៣ ប្រាក់ចំណេញជាមធ្យម របស់ផលិតករក្នុងការផលិតស្ករម្សៅ GI ..... ៤៥
៣.១.៤ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃមូលធនផលិតកម្ម..... ៤៥
៣.១.៥ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃដើមត្នោត..... ៤៦
៣.១.៦ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃកំលាំងពលកម្ម..... ៤៦
៣.២ ការវិភាគ SWOT របស់សហគមន៍..... ៤៧
៣.២.១. ចំណុចខ្លាំង ( Strengths )..... ៤៧
៣.២.២ . ចំណុចខ្សោយ ( Weakness)..... ៤៧
៣.២.៣ កាលានុវត្តភាព (Opportunities )..... ៤៧
៣.២.៤. កត្តាគំរាមកំហែង ( Threat )..... ៤៧
សេចក្តីសន្និដ្ឋាន ..... ៤៩
អនុសាសន៍..... ៥១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីពាក្យសរសេរកាត់

| ពាក្យអក្សរកាត់ | | ការពន្យល់ |
|---|---|---|
| ស.អ.ត.ក | ៖ | សហគមន៍អភិវឌ្ឍន៍កសិកម្មត្នោតកំពង់ស្ពឺ |
| Kg | ៖ | គីឡូក្រាម |
| GRET | ៖ | អង្គការហ្រ្គេត |
| CIRD | ៖ | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជនបទ |
| SWOT | ៖ | Strengths Weaknesses Opportunities and Threats |
| AFD | ៖ | ទីភ្នាក់ងារបារាំងដើម្បីការអភិវឌ្ឍន៍ |
| MAFF | ៖ | ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ |
| MOC | ៖ | ក្រសួងពាណិជ្ជកម្ម |
| GI | ៖ | ទំនិញសម្គាល់ភូមិសាស្ត្រ |
| ICCO | ៖ | INTERCHURCH ORGANIZATION FOR DEVELOPMENT CO-OPERATION |

# បញ្ជីតារាង

តារាងទី 1 ៖ ស្ថានភាពពលកម្មក្នុងគ្រួសារផលិករដែលបានចូលរួមផលិតកម្ម ........................ ១៧
តារាងទី 2 ៖ ចំនួនដើមត្នោតដែលសមាជិកផលិតករប្រើប្រាស់ក្នុងផលិតកម្ម .......................... ១៨
តារាងទី 3 ៖ ការពិពណ៌នាពីលក្ខណៈ " ស្ករត្នោតកំពង់ស្ពឺ " .................................................. ២១
តារាងទី 4 ៖ រយៈពេល រម្ងាស់និងក្អួរ ឬ វិត .............................................................................. ២៩
តារាងទី 5 ៖ រយៈពេលស្តុកទុកស្ករត្នោត .................................................................................. ៣០
តារាងទី 6 ៖ ការផ្គត់ផ្គង់ស្ករត្នោតរបស់ ស.អ.ត.ក ចាប់តាំងពីឆ្នាំ ២០១១ (គិតជាតោន) .......... ៣៦
តារាងទី 7 ៖ ការផ្គត់ផ្គង់ស្ករត្នោតរបស់ស.អ.ត.កទៅឲ្យក្រុមហ៊ុននីមួយៗក្នុងឆ្នាំ២០១៧.......... ៣៧
តារាងទី 8 ៖ តំលៃទិញ-លក់ស្ករត្នោតក្នុងរដូវកាលផលិតកម្មឆ្នាំ ២០១៧................................ ៣៨
តារាងទី 9 ៖ ចំណាយថេរជាមធ្យមរបស់ផលិតករក្នុងការផលិតស្ករម្សៅ GI ............................ ៤១
តារាងទី 10 ៖ ចំណាយប្រែប្រួលជាមធ្យមរបស់សមាជិកផលិតករក្នុងការផលិតស្ករម្សៅ GI..... ៤២
តារាងទី 11 ៖ ចំណាយសរុបជាមធ្យម ....................................................................................... ៤៣
តារាងទី 12 ៖ចំណូលសរុបជាមធ្យម .......................................................................................... ៤៤
តារាងទី 13 ៖ ប្រាក់ចំណេញជាមធ្យម........................................................................................ ៤៦
តារាងទី 14 ៖ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃមូលធនផលិតកម្ម ......................................................... ៤៦
តារាងទី 15 ៖ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃដើមត្នោត ..................................................................... ៤៧
តារាងទី 16 ៖ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃកំលាំងពលកម្ម ............................................................ ៤៧

# បញ្ជីរូបភាព

រូបភាពទី 1 ៖ការប្រមូលផលទឹកត្នោត ...................................................................................... ២៣
រូបភាពទី 2 ៖ការគាប និងចិតត្រងផ្កាត្នោតញី ................................................................................. ២៤
រូបភាពទី 3 ៖ការគាប និងចិតត្រងផ្កាត្នោតឈ្មោល ............................................................................ ២៤
រូបភាពទី 4 ៖ការស្រុះបំពង់ទឹកត្នោតមុខពេលយកទៅត្រងទឹកត្នោត ................................................... ២៥
រូបភាពទី 5 ៖រុក្ខជាតិពពេលដែលប្រជាកសិករតែងតែយកមកដាក់ក្នុងទឹកត្នោត .................................... ២៦
រូបភាពទី 6 ៖ការដុតរម្ងាស់ទឹកត្នោត .................................................................................................. ២៦
រូបភាពទី 7 ៖ការរំវិតទឹកត្នោតដើម្បីទទួលបានជាស្ករសាច់ ................................................................. ២៧
រូបភាពទី 8 ៖របៀបផលិតជាស្ករម្សៅ .................................................................................................. ២៨
រូបភាពទី 9 ៖របៀបផលិតស្ករផែន ...................................................................................................... ២៨
រូបភាពទី 10 ៖របៀបនៃការវិតស្ករ ..................................................................................................... ៣០
រូបភាពទី 11 ៖ប្រភេទនៃការវេចខ្ចប់របស់ក្រុមហ៊ុន ខន់ហ្វីរ៉ែល ........................................................... ៣២
រូបភាពទី 12 ៖ប្រភេទនៃការវេចខ្ចប់របស់ក្រុមហ៊ានសុវណ្ណៈ ............................................................... ៣២

## បញ្ជីក្រាបហ្វិក

ក្រាបហ្វិកទី 1 ៖ក្រាបបង្ហាញពីការផ្គត់ផ្គង់ស្ករត្នោត (ស.អ.ត.) ចាប់តាំងពីឆ្នាំ ២០១១............. ៣៦
ក្រាបហ្វិកទី 2 ៖ក្រាបផ្លិតបង្ហាញពីភាគរយនៃការផ្គត់ផ្គង់ស្ករត្នោតរបស់សហគមន៍ទៅតាមក្រុមហ៊ុននីមួយៗ.......................................................................................................៣៧
ក្រាបផ្លិតទី 3 ៖ក្រាបបង្ហាញពីភាគរយនៃការចំណាយរបស់ផលិតករ.................................... ៤៣

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី ១** ៖លទ្ធផលនៃការពិភាក្សាស្រាវជ្រាវដោយផ្ទាល់ លើសមាជិកផលិករ១៩នាក់ ក្នុងឃុំភ្នំតូច

**ឧបសម្ព័ន្ធទី ២**៖ បញ្ជីសមាជិកផលិតកររបស់ ស.ល.ត.ក ដែលធ្វើការលក់ដូរ ស្ករត្នោតតាមរយៈ សហគមន៍អភិវឌ្ឍន៍កសិកម្មត្នោតកំពង់ស្ពឺ

**ឧបសម្ព័ន្ធទី ៣**៖កម្រងរូបភាព និងសកម្មភាពចុះកម្មសិក្សា

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

ដើមត្នោតជារុក្ខជាតិប្រជាប្រិយតំណាងឲ្យសង្គមខ្មែរដែលមានវត្តមាន និងផ្តល់នូវគុណសម្បត្តិច្រើនយ៉ាងដល់ប្រជាជាតិខ្មែរតាំងពីយូរលង់ណាស់មកហើយ និងជាអត្តសញ្ញាណជាតិដែលប្រជាជនខ្មែរសម្គាល់នូវទេសភាព ទឹកដីរបស់ខ្លួនពីបុរាណកាលរហូតមកដល់បច្ចុប្បន្នស្រប តាមពាក្យស្លោកមួយថា " ដើមត្នោតជាជម្រកផ្ទះខ្មែរ " ដូចមានការបញ្ជាក់តាមរយៈចម្លាក់នៅលើជញ្ជាំងប្រាសាទអង្គរវត្តជាសក្ខីភាពស្រាប់។ ដើមត្នោតត្រូវបានដាំដុះរាយប៉ាយនៅតាមបណ្តាខេត្តនានា នៅក្នុងប្រទេសកម្ពុជា ហើយមួយចំនួនធំ គឺស្ថិតនៅក្នុងខេត្តតាកែវ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ។ ហើយផលិតកម្មស្ករត្នោតក៏ត្រូវបានបង្កើតឡើងនៅតាមបណ្តាខេត្តទាំងនោះផងដែរ។[1] ក្នុងនោះយើងសង្កេតឃើញថាស្ករត្នោតកំពង់ស្ពឺ ទទួលបានការពេញនិយម និងគាំទ្រយ៉ាងច្រើនពីសំណាក់អតិថិជនជាអ្នកប្រើប្រាស់ទាំងនៅក្នុងស្រុក និងនៅក្រៅប្រទេស។ ការពេញនិយមទាំងនោះកើតឡើងដោយសារតែការជឿជាក់លើ អនាម័យ និងគុណភាពផលិតផល ហើយជាពិសេសគឺរសជាតិដ៏ផ្អែមឈ្ងុយឆ្ងាញ់តាមបែបធម្មជាតិ ដោយមិនមានការលាយនូវសារធាតុគីមី ឬថ្នាំដែលនាំឲ្យប៉ះពាល់ដល់សុខភាពដល់អ្នកបរិភោគអ្វីឡើយ។ ជាក់ស្តែង ស្ករត្នោតរបស់សមាគម ត្រូវបានធ្វើតេស្តតាមដានគុណភាព ជារៀងរាល់ឆ្នាំ ពី ភ្នាក់ងារ Ecocert Sa ប្រទេសបារាំង និងត្រូវបានចុះបញ្ជីការជាផលិតផលសម្គាល់ភូមិសាស្ត្រ (GI) នៅក្រសួងពាណិជ្ជកម្មក្នុងឆ្នាំ ២០១០ ផងដែរដើម្បីការពារទប់ទល់នឹងការក្លែងបន្លំ សំដៅលើកកម្ពស់នូវតម្លៃនិង កេរ្តិ៍ឈ្មោះ ផលិតផលពិតប្រាកដ ការពារអ្នកបរិភោគ និងបង្កើនប្រាក់ចំណូលដល់ផលិតករជនបទ។[2]

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ស្ករត្នោតកំពង់ស្ពឺ ត្រូវបានទទួលស្គាល់ទាំងគុណភាព និងរសជាតិ ទាំងទីផ្សារក្នុងស្រុក និងក្រៅស្រុក ជាពិសេសគឺទទួលបានការបញ្ជាទិញជារៀងរាល់ឆ្នាំ ពោលគឺប្រមាណ ៣០០ តោន នៅឆ្នាំ ២០១៧។ ហេតុនេះផលិតកម្មស្ករត្នោតបានចូលរួមចំណែកផ្នែកសេដ្ឋកិច្ចដល់គ្រួសារផលិតករស្ករត្នោតនានានៅទីជនបទ។ ហេតុនេះដើម្បីស្វែងយល់អំពី ប្រសិទ្ធភាពសេដ្ឋកិច្ចនៃផលិតកម្មស្ករត្នោត សំនួរមួយចំនួនក៏ត្រូវបានលើកឡើងដើម្បីធ្វើការស្រាវជ្រាវ ៖

[1] MAHE, Jean Pierre. Marketing opportunities for the products of the sugar palm trees in Cambodia , 2000

[2] បទសម្ភាសន៍ផ្ទាល់ជាមួយលោក សំ សារឿន ប្រធានសមាគមលើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ

– តើខ្សែចង្វាក់ផលិតកម្មស្ករត្នោតមានដំណើរការយ៉ាងដូចម្តេច?

– តើតំលៃរបស់ស្ករត្នោតត្រូវបានកំណត់ដោយនរណា និងមានប្រព្រឹត្តទៅយ៉ាងដូចម្តេច?

– តើប្រតិបត្តិការទីផ្សារ ត្រូវបានធ្វើឡើងដោយរបៀបណា?

– តើប្រសិទ្ធភាពសេដ្ឋកិច្ចរបស់ផលិតកម្មមានលក្ខណៈយ៉ាងដូចម្តេចដែរ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ប្រធានបទខាងលើត្រូវបានលើកយកមកសិក្សាស្រាវជ្រាវ ដោយផ្តោតលើគោលបំណងបីសំខាន់ៗគឺ៖

- ការសិក្សាលើទ្រឹស្តីពាក់ព័ន្ធជុំវិញផលិតកម្មស្ករត្នោត
- ការសិក្សាលើប្រតិបត្តិការផលិតកម្មស្ករត្នោតរបស់សហគមន៍
- ប្រសិទ្ធភាពសេដ្ឋកិច្ចនៃផលិតកម្មស្ករត្នោតកំពង់ស្ពឺ នៅក្នុងឃុំភ្នំតូច
- ការវិភាគ SWOT របស់ផលិតករស្ករត្នោតកំពង់ស្ពឺ។

## ៤. ទំហំ និងដែនកំណត់

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងតែទៅលើស្ករត្នោតកំពង់ស្ពឺ ដែលគ្រប់គ្រងដោយសមាគមលើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ និងសហគមន៍អភិវឌ្ឍន៍កសិកម្មត្នោតកំពង់ស្ពឺប៉ុណ្ណោះ។ ដោយសារពេលវេលាមានកំណត់ ទើបសម្រេចយកឃុំភ្នំតូច នៃស្រុកឧដុង្គ ធ្វើជាតំបន់សិក្សា។ ទន្ទឹមនឹងនេះ ការសិក្សាបានកំណត់ចំនួន ១៩គ្រួសារ សហគ្រាសវេចខ្ចប់ចំនួន ៣ និងក្រុមប្រឹក្សាភិបាលរបស់ សមាគម និងសហគមន៍ចំនួន ៥រូបដែលបម្រើការងារ និងរស់នៅក្នុងតំបន់សិក្សាពោលគឺ ឃុំ ភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ក្នុងការស្រាវជ្រាវចងក្រងប្រធានបទ ″ **ប្រសិទ្ធភាពសេដ្ឋកិច្ចនៃផលិតកម្មស្ករត្នោតក្រោមស្លាកសញ្ញាទំនិញសម្គាល់ភូមិសាស្ត្រ** ″ នេះឡើង យើងបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបគុណភាព (Qualitative Method )។

### ៥.១ វិធីសាស្ត្រប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ គឺចាំបាច់បំផុតដើម្បីឆ្លើយតបនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវ។ ហេតុនេះទើបប្រភពទិន្នន័យដែលយកមកសិក្សាត្រូវពឹងផ្អែកលើប្រភពសំខាន់ពីរយ៉ាងគឺ ទិន្នន័យមានស្រាប់ និងទិន្នន័យចំបងដែលបានពីការចុះសម្ភាសន៍ផ្ទាល់ជាមួយផលិតករ និងអ្នកពាក់ព័ន្ធទាំងអស់ដោយប្រើបញ្ជីសំណួរ។

**ក. ទិន្នន័យចំបង**

ការប្រមូលទិន្នន័យនេះប្រព្រឹត្តទៅតាមរយៈ ការសាកសួរព័ត៌មានជាមួយគ្រួសារផលិតករ សហគមន៍ បុគ្គលសំខាន់ៗ ដែលត្រូវបានកំណត់ទៅតាមគោលបំណងសិក្សា។

**ខ. ទិន្នន័យមានស្រាប់**

ទិន្នន័យមានស្រាប់ ជាទិន្នន័យដែលបានមកពីឯកសារ និងរបាយការណ៍ផ្សេងៗ មានស្រាប់ ដែលជាប់ពាក់ព័ន្ធនឹងប្រធានបទសារណា។

ទិន្នន័យនេះ បានមកពីការប្រមូលឯកសារសំខាន់ៗ មកពីប្រភពដូចខាងក្រោម៖

- បណ្ណាល័យ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សមាគមលើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ
- សហគមន៍អភិវឌ្ឍន៍កសិកម្មត្នោតកំពង់ស្ពឺ
- សាលាឃុំភ្នំតូច
- សារពត៌មាន
- ប្រព័ន្ធអ៊ីនធឺណិត

**៦.សារៈសំខាន់នៃការស្រាវជ្រាវ**

- ទទួលបានចំណេះដឹង និងបទពិសោធន៍យ៉ាងច្រើនពីការចុះស្រាវជ្រាវមួយនេះ។
- បានចូលរួមការពារ និងអភិរក្សដើមត្នោតរបស់ខ្មែរអោយបានឋិតថេរ គង់វង្ស យូរអង្វែង។
- ចូលរួមគាំទ្រ និងលើកកម្ពស់ ក៏ដូចជាជួយផ្សព្វផ្សាយ នូវផលិកម្មស្ករត្នោតកំពង់ស្ពឺរបស់ប្រទេសកម្ពុជាបន្ថែមទៀត។
- ដើម្បីចងក្រងទុកជាឯកសារ និងជាទុនសម្រាប់អ្នកសិក្សាជំនាន់ក្រោយដែលចង់សិក្សាស្រាវជ្រាវបន្ថែមទៀត។
- ចង់សិក្សាដឹងអោយច្បាស់អំពីខ្សែចង្វាក់តម្លៃស្ករត្នោតកំពង់ស្ពឺ។

**៧.រចនាសម្ព័ន្ធស្រាវជ្រាវ**

អត្ថបទសារណាក្រោមប្រធានបទ " **ប្រសិទ្ធភាពសេដ្ឋកិច្ចនៃផលិតកម្មស្ករត្នោតក្រោមស្លាកសញ្ញាទំនិញសម្គាល់ភូមិសាស្ត្រ** " ត្រូវបានចែកចេញជា ៥ ផ្នែកធំៗ៖

- សេចក្តីផ្តើម៖ គឺ ជាផ្នែកដំបូងបង្អស់ដែលបរិយាយអំពី មូលហេតុ គោលបំណង ទំហំ និង រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ។
- ជំពូកទី ១ រំលឹកទ្រឹស្តី និងសំយោគឯកសារពាក់ព័ន្ធ
- ជំពូកទី ២ ស្ថានភាពទូទៅនៃសហគមន៍អភិវឌ្ឍន៍កសិកម្មត្នោតកំពង់ស្ពឺ
- ជំពូកទី ៣ ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍។

# ជំពូកទី១

# រំលឹកទ្រឹស្តី និងសំយោគឯកសារពាក់ព័ន្ធ

## ១.១ ប្រវត្តិនៃដើមកំណើតរុក្ខជាតិត្នោតនៅលើពិភពលោក

នៅលើពិភពលោក ដើមត្នោតមានចំនួន ២០០អម្បូរធំៗ និង ១៥០០ ប្រភេទដែលមានតាំងពីធម្មជាតិក្នុងតំបន់ត្រូពិច និងអនុតំបន់ត្រូពិច។ ក្នុងនោះផងដែរ ដើមត្នោតជារុក្ខជាតិដែលមានសរសៃរឹង និងមានឈ្មោះវិទ្យាសាស្ត្រថា Borassus flabellifer ស្ថិតនៅក្នុងអម្បូរ Palmae នៃគ្រួសារ Arecaceae។ គេសង្កេតឃើញថា ដើមត្នោតមានដុះនៅទ្វីបអាស៊ីនៃតំបន់ត្រូពិច អាព្រិច អាមេរិកខាងត្បូង អាមេរិកកណ្តាល និងអូសេអានី ជាពិសេសសម្បូរទៅតាមបណ្តាប្រទេសមួយចំនួនដូចជា អាហ្វ្រិក ម៉ាដាហាស្កា បង់ក្លាដេស ឥណ្ឌា ស្រីលង្កា អង់គ្លេស ឥណ្ឌូចិន អាស៊ីអាគ្នេយ៍ ភូមា ថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និង កម្ពុជា។[3]

ជាយូរលង់ណាស់មកហើយ គេមិនអាចកំណត់បាននូវដើមកំណើតរបស់ដើមត្នោតឲ្យបានច្បាស់លាស់នៅឡើយទេ។ ប៉ុន្តែជាភស្តុតាងជំរំរុក្ខសាស្ត្ររបស់ត្នោតទំនងជាស្ថិតនៅភូមិភាគខាងត្បូងនៃប្រទេសឥណ្ឌា និងប៉ែកខាងជើងនៃប្រទេសស្រីលង្កា ដែលជនជាតិអង់គ្លេសឲ្យឈ្មោះថា Palmyra Palm។ ម្យ៉ាងទៀតប្រទេសឥណ្ឌា និងប្រទេសស្រីលង្កាមានកម្មវិធីសិក្សាស្រាវជ្រាវថ្នាក់ជាតិស្តីពីដើមត្នោត (Borassus flabellifer ) នេះផងដែរ។

## ១.២ រុក្ខជាតិត្នោតនៅកម្ពុជា

### ១.២.១ ដើមកំណើតរុក្ខជាតិត្នោតនៅកម្ពុជា

ដើមត្នោត ( Borassus flabellifer) ក្រៅពីមានដុះតាមបណ្តាប្រទេសមួយចំនួននៅលើពិភពលោកដើមត្នោតប្រភេទនេះ ត្រូវបានគេជឿជាក់ថាមានដុះច្រើននៅអាស៊ីអាគ្នេយ៍ ប៉ុន្តែមានតែប្រទេសកម្ពុជាមួយទេដែលមានដើមត្នោតដុះច្រើនពាសពេញផ្ទៃដីច្រើនជាងគេ និងជាអត្តសញ្ញាណជាតិទីពីរបន្ទាប់ពីប្រាសាទអង្គរវត្ត ។[4] ជាភស្តុតាងនៅចន្លោះសតវត្សទី១ និងទី ៧ ជនជាតិឥណ្ឌាបាននាំរុក្ខជាតិត្នោតមកពីប៉ែកខាងត្បូងនៃប្រទេសឥណ្ឌា និងនៅប៉ែកខាងជើងនៃប្រទេសស្រីលង្កា ចូលមកប្រទេសកម្ពុជាក្នុងសម័យហ្វូណន ជាមួយ និងឧបករណ៍នង្គ័លសម្រាប់ភ្ជួររាស់ធ្វើអំពីដើម

[3] ព្យែរ ដូប៊ែរ.១៩៩១.បច្ចេកទេសកសិកម្មនិងការអភិវឌ្ឍន៍នៅកម្ពុជាគម្រោងហ្គ្រេត :ផលិតកម្ម សិប្បកម្មស្ករត្នោតនៅកម្ពុជា

[4] ក្រសួងបរិស្ថាន. ២០០៤ ស្ថានភាពបរិស្ថាននៅកម្ពុជា

ត្នោតផងដែរ។ ដើមត្នោតមានចំនួនកើនឡើងតាំងពីមានក្រឹត្យច្បាប់របស់ព្រះមហាក្សត្រនរោត្តម នៅឆ្នាំ១៩០១ ព្រះមហាក្សត្រនរោត្តម បានត្រាស់បង្គាប់ថា ត្រូវតែដាំដើមត្នោតយ៉ាងហោចណាស់ ពីរទៅបីដើមក្នុងមួយគ្រួសារ យុទ្ធនាការនេះទទួលបានជោគជ័យយ៉ាងខ្លាំងដែលមានដើមត្នោត ច្រើនជាងគេ ផ្ទុយទៅវិញតំបន់នានា នៃប្រទេសកម្ពុជាដែលស្ថិតនៅក្រោមអំណាចសៀម ( ថៃ ) ដូចជានៅខេត្តបាត់ដំបងជាដើម។[5] ដើម្បី លើកស្ទួយកម្រិតជីវភាពរបស់ប្រជាកសិករ ធ្វើអោយ ដើមត្នោតមានចំនួនច្រើន និងដុះរាយប៉ាយស្មើរគ្រប់ ខេត្ត ក្រុងទាំងអស់ ហើយជាពិសេសភាគ ច្រើនគឺនៅខេត្ត កណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង និងពោធិ៍សាត់។ ប៉ុន្តែរយៈឆ្នាំប៉ុន្មានឆ្នាំចុងក្រោយ នេះ មានការប្រមូលទិញដើមត្នោត ពីប្រជាកសិករយកមកធ្វើជាគ្រឿងសំណង់ និងគ្រឿងសង្ហារឹម ផ្សេងៗក្នុងតម្លៃពី ១០០០០រៀល ទៅ ៥០០០០រៀល ក្នុងមួយដើមនិងការកាប់រំលំដើមត្នោតយកដី ធ្វើជាតំបន់អភិវឌ្ឍន៍នានា ធ្វើឲ្យចំនួនដើមត្នោតមានការថយចុះយ៉ាងខ្លាំង។

### ១.២.២ ប្រភេទពូជនៃរុក្ខជាតិត្នោត[6]

នៅក្នុងបណ្តាប្រទេសជិតខាងយើងរួមមាន ថៃ ឡាវ និងវៀតណាម យើងសង្កេតឃើញថា ប្រទេសកម្ពុជា សម្បូររុក្ខជាតិត្នោតជាងគេ តាមការពិនិត្យលើ លក្ខណៈរូប ផ្លែ ពណ៌ ទំហំ ទ្រង់ទ្រាយ និងទិដ្ឋភាពជាក់ស្តែង យើងអាចចែករុក្ខជាតិត្នោតជាបីពូជ៖

**ត្នោតត្រាំង ៖** ក្នុងចំណោមពូជត្នោតទាំងបី គេសង្កេតឃើញថាប្រភេទពូជត្នោតនេះមានផ្លែធំ ជាងគេ ដោយសារតែវាមានវិមាត្រចាប់ពី ១៥ ទៅ ១៦ ស.ម ប៉ុន្តែផ្លែរបស់វាប្រែជាពណ៌ខ្មៅនៅ ពេលទុំ។ អាជីវករត្នោតចូលចិត្តពូជត្នោតនេះណាស់ ព្រោះពួកគាត់អាចទាញយកទឹកត្នោតបាន ច្រើន ពីប្រភេទពូជត្នោតនេះ។

**ត្នោតសម្ល ៖** ប្រភេទពូជត្នោតនេះមានលក្ខណៈរូបដូចពូជត្នោតត្រាំងដែរ ប៉ុន្តែអេពីឌែមមាន ពណ៌សបន្តិច។ ហើយជាពិសេសប្រភេទពូជត្នោតនេះប្រជាពលរដ្ឋនិយមយកផ្លែខ្ចីមកស្ល និងធ្វើ ជាបង្អែមផ្សេងៗទៀតផង។

**ត្នោតអាចម៍សេះ ៖** ផ្លែត្នោតពូជនេះមានវិមាត្រនៃផ្លែតូចជាងគេគឺពី ៣ ទៅ ៤ ស.ម ប៉ុណ្ណោះ នៅពេលទុំផ្លែមានពណ៌ខ្ចី ហើយមានរសជាតិខារ។ ដោយសារតែផ្លែមានរសជាតិខារ ព្រមទាំង

---

[5] Borin, Khieu. The Sugar Palm Tree As the Basis of Integrated Farming Systems in Cambodia.2002.

[6] ឈុន សុខលី. ១៩៩២. ដំណាំត្នោតនៅកម្ពុជា

ដើមត្នោតប្រភេទនេះគៀបយកទឹកបានតិច និងមានកម្រិតជាតិស្ករតិចផងនោះ នាំឲ្យប្រជាពលរដ្ឋមិនសូវជាចូលចិត្តពូជត្នោត ប្រភេទនេះទេ។

### ១.២.៣ លក្ខណៈជីវសាស្ត្ររបស់រុក្ខជាតិត្នោត

**ប្រព័ន្ធឫស** : ប្រព័ន្ធឫសត្នោតលូតលាស់ខ្លាំងណាស់ ប៉ុន្តែឫសរបស់វាមិនសូវបែកខ្នែកពាសពេញផ្ទៃដីខាងលើនោះទេ។ ជាទូទៅ ត្នោតមានឫសកែវធំមួយដែលដុះចាក់ចូលទៅក្នុងដី ដែលឫសទាំងនោះមានរាងជាស៊ីឡាំងមានវិមាត្រពី ៣ ទៅ ៥ ស.ម។ ឫសភាគច្រើនចាក់ចូលទៅក្នុងដីជ្រៅជាង ៤ ទៅ ៥ ស.ម។ ជាទូទៅឫសឆ្មារដែលមានមុខងារ ស្រូបយកសារធាតុរ៉ែ និងសរីរាង្គចាក់រាយពាសពេញផ្ទៃដីដែលមានជម្រៅមិនលើសពី ៣០ ស.ម ទេ។ ឫសដែលជាឫសកំណើតមានរាងតូច ទ្រវែង ដែលមានរាងជាស៊ីឡាំង មានវិមាត្រមិនលើសពី ១ ស.ម និងមានបណ្តោយពី ៥ ទៅ ១០ ស.ម។ ដំបូងឡើយឫសមានពណ៌ស្រអាប់ បន្ទាប់មកវាមានពណ៌ក្រហមថ្លា នៅពេលចាស់ឫសរបស់វា មានពណ៌ឡើងក្រហមជាំ ឬក៏ក្រហមក្រមៅ ព្រោះមានសរសៃចាស់ពណ៌ខ្មៅ។

**គល់ត្នោត ៖** គល់ត្នោត ជាផ្នែកខាងក្រោមនៃដើមត្នោតមានរាងជា សាជីប៉ោងកណ្តាល។ ហើយគល់នៃសំណុំឫស ជាសរីរាង្គមានមាឌធំ ចាក់ជ្រៅជម្រៅពី ៤០ ទៅ ៥០ ស.ម។ ចេញពីផ្ទៃគល់ត្នោតទាំងមូល ឫស សំខាន់ៗដុះយ៉ាងឆាប់រហ័សត្រង់ចុះទៅក្រោម ឯឫសមួយចំនួនទៀតដែលដុះនៅជុំវិញគល់ដុះចាក់ចេញសងខាងគល់ពាសពេញផ្ទៃដីជម្រៅ ១០ ស.ម។

**ដើមត្នោត ៖** ដើមត្នោតមានរាងធំសំបើម និងគ្មានបន្លាទេដើមមានរាងប្រហាក់ប្រហែលនិងស៊ីឡាំង ប៉ុន្តែផ្នែកគល់ និងចុងរាងគគ្រើមពណ៌ប្រផេះស្រអាប់មានកម្ពស់ពី ២០ ទៅ ២៥ ម៉ែត្រ ហើយ ដើមត្នោតមានស្នាមជារង្វង់ក្របីៗព័ន្ធជុំវិញដើម ដែលជាស្នាមធាងងាប់។ ដើមមានរាងប៉ោងគល់ដែលមានវិមាត្ររហូតទៅដល់ ជាងមួយម៉ែត្រ។ ត្នោតមានភេទញី និងភេទឈ្មោលដែលស្ថិតនៅដើមផ្សេងៗពីគ្នា ហើយលក្ខណៈខុសប្លែកគ្នាទៅតាមការសម្គាល់លើផ្ការបស់វា។ ទោះបីជាយ៉ាងក៏ដោយ ប្រសិនបើនិយាយអំពីត្នោតញី ឬឈ្មោលគេមិនអាចទាន់បញ្ជាក់បានថាត្នោតមួយនេះជាត្នោតញី ឬឈ្មោលបានទេប្រសិនបើត្នោត នោះមិនទាន់ចេញផ្កា ប៉ុន្តែមានកសិករខ្លះបាននិយាយថាបើតាមការអង្កេតរបស់គាត់ឃើញថា ត្នោតឈ្មោលមានស្លឹកទន់ជាងត្នោតញី។

**ស្លឹកត្នោត ៖** ក្នុងមួយធាងមានស្លឹកពី ៤០ ទៅ ៥០ ហើយក្នុងស្លឹកនីមួយៗមានប្រវែងពី ១.២ ទៅ ២ ម៉ែត្រ បង្កើតបានជាកម្រងយ៉ាងស្រស់ព័ន្ធជុំវិញកំពូកត្នោត ដែលមានរាងឆែកៗគួរឲ្យចង់គយគន់។ ស្លឹក និងដើមត្រូវបានភ្ជាប់គ្នាដោយធាង ហើយធាងមានរាងសំប៉ែត វែង ក្រហូង កណ្តាលដែលមានរាង ដូចជាទូក។

**ផ្កាត្នោត ៖** ជាទូទៅផ្កាត្នោតចាប់ផ្តើមចេញផ្កានៅរដូវប្រាំង ចាប់ពីខែ វិច្ឆិកា ដល់ ខែ មករា។ ផ្កាត្នោតឈ្មោលចាប់ផ្តើមវិវត្តន៍នៅក្នុងខែ វិច្ឆិកា ឬ ខែ ធ្នូ ក្នុងខណៈពេលដែលផ្កាញីចាប់ផ្តើមចេញផ្កាក្នុងរយៈពេល ១ ឬ ២ ខែបន្ទាប់។ នៅក្នុងដើមត្នោតមួយដើមៗ អាចចេញផ្កាពី ៨ ទៅ ១៥ ផ្កាក្នុងមួយឆ្នាំ។ ផ្កាឈ្មោល ឈប់ចេញផ្កាក្នុងរយៈពេលប្រមាណជា ៤៥ ទៅ ៦០ ថ្ងៃ ចំណែកផ្កាញីវិញឈប់ចេញផ្កាក្នុងរយៈពេលពី ៦០ ទៅ ៧០ ថ្ងៃ។ ទាំងផ្កាញី និងផ្កាឈ្មោលត្រូវបានគាបយកទឹកទាំងអស់ សម្រាប់ការ ប្រមូលយកទឹកត្នោតសម្រាប់ធ្វើស្ករត្នោត។

### ១.២.៤ អត្ថប្រយោជន៍របស់រុក្ខជាតិត្នោត[7]

រុក្ខជាតិត្នោត ជាដើមឈើមួយប្រភេទ របស់កម្ពុជា ដែលមានគុណប្រយោជន៍ យ៉ាងខ្លាំង ចាប់តាំងពី ឫស ដើម ស្លឹក ធាង ផ្កា ផ្លែ។ រុក្ខជាតិប្រភេទនេះបានផ្តល់សារៈប្រយោជន៍ជាច្រើន សម្រាប់ឲ្យមនុស្ស យកទៅកែច្នៃសម្រាប់ធ្វើជាសំភារៈ ប្រើប្រាស់ផ្សេងៗ ឱសថព្យាបាលជម្ងឺ និង ថែមទាំងអាចយកទៅធ្វើជាអាហារបានទៀតផង។ ក្រៅពីផ្លែខ្ចី យកមកធ្វើបង្អែមយ៉ាងឆ្ងាញ់ពិសា និងផ្លែទុំ យកមកធ្វើនំ អាកោត្នោតយ៉ាងឆ្ងាញ់ ទឹកត្នោតយកមកធ្វើជាភេសជ្ជៈផ្អែម ជូរ និងរម្ងាស់ធ្វើជាស្ករត្នោតហើយនោះ ឫសត្នោតមានរសជាតិផ្អែមត្រជាក់ យកមកដាំទឹកពិសា ជួយកែអាការៈក្តៅក្នុង គ្រុនក្តៅ និងរលាកក្រពេញ ទឹកមាត់ បាន។ អ្នកខ្លះ ប្រើជាថ្នាំប៉ូវកម្លាំង ជួយបណ្តេញឈាម និងទម្លាក់ព្រូន ឬសត្វល្អិត បំបាត់គ្រុនក្តៅ ចេញស្អូចលើកុមារ។ រីឯធាងត្នោត ប្រសិនបើធាងស្រស់ ត្រូវយកទៅអាំងភ្លើង ឬរោល ហើយពូតយកទឹកមកទទួលទាន កែអាការៈរាករូស ឈឺស្លឹកស្រពន់។ ចំពោះផ្កាត្នោត ដែលមានរសជាតិផ្អែមត្រជាក់ ប្រើសម្រាប់កែគ្រុនក្តៅ បំបាត់ស្អូចជួយទម្លាក់ព្រូន ។ ចំពោះស្លឹកត្នោត បើលីងអោយឡើង ហើយបុករហូតក្លាយ ទៅជាម្សៅម៉ត់ផងអាចជក់ ឬបុរាណលោកថា អាចជួយកាត់បន្ថយសម្ពាធឈាម សម្រាប់អ្នកមានជំងឺលើសឈាម ហើយយើងអាចទាញផលពីរុក្ខជាតិត្នោត បានផ្សេងទៀតដូចជា ទឹកត្នោត ស្ករត្នោត ផ្ទះប្រក់ស្លឹកត្នោត ជញ្ជាំងស្លឹកត្នោត កន្ទេលស្លឹកត្នោត សំពៀតស្លឹកត្នោត ផ្ចិតស្លឹកត្នោត ដូនស្លឹកត្នោត ក្បាបត្នោត សម្លត្នោតសម្លគមត្នោត នំត្នោត ចាហួយត្នោត កំពឹងត្នោត ម្សៅត្នោត សាច់ត្នោតខ្ចី ត្នោតទុំដុត គល់កូនត្នោតស្ងោរឬដុត ខ្សែធាងត្នោត ខ្សែជក់ត្នោត រនូតដើមត្នោត អំបោសជក់ត្នោត។

## ១.៣ សហគមន៍កសិកម្ម

### ១.៣.១ និយមន័យនៃសហគមន៍កសិកម្ម

[7] ចេង សុខហ៉ង.២០១៦.អង្គការទិន្នន័យអំពីការអភិវឌ្ឍន៍.

សហគមន៍កសិកម្ម[8] គឺជានីតិបុគ្គលឯកជនដែលមានលក្ខណៈជាសហគ្រាសសេដ្ឋកិច្ចកសិកម្ម ដែលបង្កើតឡើងដោយរូបវន្តបុគ្គលមួយក្រុម តាមការស្ម័គ្រចិត្ត រួមគ្នាបង្កើតដើមទុន រួមគ្នាធ្វើជាម្ចាស់ និងរួមគ្នាគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យ ដើម្បីពង្រីកសមត្ថភាពផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម សំដៅលើកកម្ពស់សេដ្ឋកិច្ច សង្គម និងវប្បធម៌ របស់សមាជិកស្របតាមគោលការណ៍គ្រឹះមានដូចខាងក្រោម៖

- ការចូលរួមដោយស្ម័គ្រចិត្ត និងបើកចំហសមាជិកភាព
- ការគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យដោយសមាជិក
- ការចូលរួមផ្នែកសេដ្ឋកិច្ចរបស់សមាជិក
- ស្វ័យភាព និងឯករាជ្យ
- ការអប់រំ ការបណ្តុះបណ្តាល និងការផ្តល់ព័ត៌មាន
- ការធ្វើសហប្រតិបត្តិការជាមួយសហគមន៍កសិកម្មផ្សេងទៀត។

### ១.៣.២ គោលនយោបាយគាំទ្ររបស់រាជរដ្ឋាភិបាលចំពោះសហគមន៍កសិកម្ម

#### ក. ការបង្កើតច្បាប់ស្តីពីសហគមន៍កសិកម្ម

ច្បាប់ស្តីពីសហគមន៍កសិកម្ម ត្រូវបានបង្កើត និងដាក់ឲ្យប្រើប្រាស់ នៅខែមិថុនា ឆ្នាំ ២០១៣ ក្នុងគោលបំណងលើកកម្ពស់ការចូលរួមដោយស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលមានមុខរបរចម្បងក្នុងក្របខណ្ឌនៃប្រព័ន្ធផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម ក្នុងការបង្កើត និងការអភិវឌ្ឍន៍សហគមន៍កសិកម្ម សំដៅលើកកម្ពស់សេដ្ឋកិច្ច សង្គមនិងវប្បធម៌របស់សមាជិកព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ[9]។

#### ខ.ស្ថាប័នមានសមត្ថកិច្ចលើសហគមកសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការជំរុញ និង គាំទ្រក្នុងការបង្កើត ការចុះបញ្ជី ប្រតិបត្តិការ និងការអភិវឌ្ឍរបស់សហគមន៍កសិកម្ម ដោយអនុលោមតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្នុងនោះ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ដែលស្ថិតនៅក្រោមអគ្គនាយកដ្ឋានកសិកម្ម ជាអ្នកទទួល

---

[8] មាត្រាទី៤ នៃច្បាប់ ស្តីពីសហគមន៍កសិកម្ម ២០១៣

[9] មាត្រាទី១ នៃច្បាប់ ស្តីពីសហគមន៍កសិកម្ម. ២០១៣

បន្ទុកដោយផ្ទាល់លើការងារអភិវឌ្ឍន៍សហគមន៍កសិកម្មដែលត្រូវកំណត់ដោយអនុក្រឹត្យ។[10]

**គ. មូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម**

រដ្ឋាភិបាលបានបង្កើតនូវ មូលនិធិមួយ ដែលមានឈ្មោះថា "មូលអភិវឌ្ឍសហគមន៍កសិកម្ម" ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃការគាំទ្រ និងការអភិវឌ្ឍសហគមន៍កសិកកម្ម។ មូលនិធិនេះរួមមានទ្រព្យសម្បត្តិដែលមានប្រភពដូចខាងក្រោម៖

១. វិភាគទានធនពីរដ្ឋ។

២. អំណោយសប្បុរសជនថវិកាឫទ្រព្យសម្បត្តិ។

៣. ហិរញ្ញប្បទានពីរដ្ឋឫពីប្រភពផ្សេងទៀត។

៤. ការលក់ទ្រព្យសម្បត្តិដែលបានមកពីចំណុច (២) និង (៣)។

៥. ការចូលរួមវិភាគទានរបស់សហគមន៍កសិកម្ម។[11]

## ១.៤ សេដ្ឋកិច្ចនៅជនបទ[12]

សេដ្ឋកិច្ចជនបទ គឺផ្តោតសំខាន់ទៅលើកម្រិតជីវភាពរស់នៅរបស់ប្រជាជននៅតាមទីជនបទនិងមុខរបរចិញ្ចឹមជីវិតរបស់ពួកគាត់។ មុខរបរភាគច្រើននៅជនបទ គឺពឹងផ្អែកទៅលើវិស័យកសិកម្ម តួយ៉ាងការធ្វើកសិកម្មនៅជនបទ ពុំទាន់មានបច្ចេកទេសគ្រប់គ្រាន់ និងការប្រើប្រាស់ធនធានពុំទាន់អស់លទ្ធភាពនៅឡើយ។ ការប្រើប្រាស់ធនធានទាំងនោះរួមមាន៖ ការប្រើប្រាស់ដីធ្លីក្នុងមួយឆ្នាំមិនទាន់អស់ពីលទ្ធភាព ការចិញ្ចឹមសត្វក្នុងបរិមាណតិចតួច ការប្រើប្រាស់សត្វពាហនៈជាកម្លាំងអូសទាញ ការប្រើប្រាស់ឥណទានជនបទ និងការចំណាយមូលធនក្នុងមុខរបរ ផ្សេងៗមិនទាន់ចំទិសដៅល្អ ពលកម្មគ្រួសារ និងមធ្យោបាយពលកម្មច្រើន ធៀបនឹងផលិតកម្មដែលបង្ហាញពីភាពពិតនៃការងារផលិតកម្ម ប្រាក់ចំណូល និងការចំណាយរបស់កសិករ។ ប្រភពប្រាក់ចំណូលរបស់គ្រួសារកសិករនៅជនបទមានបីប្រភេទសំខាន់ៗដូចជា៖

**ក. ប្រភពចំណូលពីកសិកម្ម៖** ប្រភពចំណូលនេះគឺគិតលើអ្វីៗ ដែលប្រជាកសិករទទួលបានពីការធ្វើស្រែចំការ និងការចិញ្ចឹមសត្វផ្ទាល់ខ្លួនតែប៉ុណ្ណោះ។

[10] មាត្រាទី៨ នៃច្បាប់ ស្តីពីសហគមន៍កសិកម្ម. ២០១៣

[11] មាត្រាទី១១ នៃច្បាប់ ស្តីពីសហគមន៍កសិកម្ម

[12] L, Philippe. Rural Socio Economics 1996 . Page 124

**ខ.ប្រភពចំណូលបានមកពីមុខរបរក្រៅកសិដ្ឋាន៖** កសិករទទួលបានពីការរកស៊ីឈ្នួលគេ ក្នុងការងារកសិកម្ម ដោយការលក់កម្លាំងពលកម្មឲ្យកសិដ្ឋានខាងក្រៅដែលមិនមែនជាកសិដ្ឋាន របស់ខ្លួន។ ការងារទាំងនេះរួមមានដូចជា៖ ការភ្ជួររាស់ ស្ទូង ច្រូតកាត់ បោកបែន កិនស្រូវ និងការដឹកជញ្ជូនផ្សេងៗ។

**គ.ប្រភពចំណូលបានពីមុខរបរមិនមែនកសិកម្ម៖** កសិករទទួលបានប្រាក់ចំណូលពីសកម្មភាពការងារផ្សេងៗទៀត ដែលមានលក្ខណៈខុសពីកសិកម្មទាំងស្រុងរួមមាន៖ លក់ដូរ ការងារមន្ត្រីរាជការ ជាងកាត់សក់ និងអ្នករត់ម៉ូតូឌុបជាដើម។

ដូចនេះ សេដ្ឋកិច្ចជនបទរឹងមាំអាស្រ័យប្រភពចំណូលទាំងបីខាងលើ។

## ១.៥ ច្បាប់តម្រូវការ និង ផ្គត់ផ្គង់

### ១.៥.១ ច្បាប់តម្រូវការ[13]

តំរូវការ បង្ហាញពីបំណងចង់បានទ្រព្យ និងសេវា និងលទ្ធភាពនៃការទូទាត់ដើម្បីទទួលបានវា។ ថ្លៃ គឺជាកត្តាសំខាន់មួយដែលមានឥទ្ធិពលទៅលើតម្រូវការ។ នៅកម្រិតថ្លៃនីមួយៗ បរិមាណតម្រូវការគឺជាបរិមាណដែលអ្នកទិញ ចង់ទិញនៅថ្លៃនោះ។

នៅក្នុងច្បាប់តម្រូវការអះអាងថា បើកត្តាឥទ្ធិពលផ្សេងទៀតមិនប្រែប្រួលនៅដំណាក់កាលជាក់លាក់មួយ ហើយបើថ្លៃមុខទំនិញមួយកាន់តែថោក នោះបរិមាណតម្រូវការទំនិញនោះកាន់តែកើនឡើង។ ផ្ទុយទៅវិញ បើថ្លៃទំនិញកាន់តែកើន នោះបរិមាណតំរូវការទំនិញកាន់តែតិច។

### ១.៥.២ ច្បាប់ផ្គត់ផ្គង់

ផ្គត់ផ្គង់ បង្ហាញពីបំណង និងលទ្ធភាពរបស់អ្នកផលិត ក្នុងការផ្គត់ផ្គង់ទ្រព្យ និងសេវាលើទីផ្សារ។ អ្នកដែលផ្គត់ផ្គង់ទ្រព្យ ឬសេវា លើទីផ្សារ គឺជាផលិតករ។ ដូចតម្រូវការដែរ ថ្លៃគឺជាកត្តាសំខាន់ ដែលមានឥទ្ធិពលទៅលើការផ្គត់ផ្គង់ ។

ច្បាប់ផ្គត់ផ្គង់ បង្ហាញថាអ្នកផលិតមានបំណងលក់ទ្រព្យ និងសេវាកាន់តែច្រើននៅថ្លៃខ្ពស់ លក់កាន់តែតិចនៅថ្លៃទាប។ ផលិតករចង់បានប្រាក់ចំណេញ ដូច្នេះនៅពេលដែលទ្រព្យ និងសេវាកើននោះ គេមានបំណងផ្គត់ផ្គង់ច្រើន តែនៅពេលដែលថ្លៃធ្លាក់ទាប គេនឹងផ្គត់ផ្គង់កាន់តែតិច។ និយាយម្យ៉ាងទៀត គេអាចនិយាយថា ថ្លៃ និងបរិមាណផ្គត់ផ្គង់មានទំនាក់ទំនងស្របគ្នា។

## ១.៦ ការវិភាគ SWOT ( ស្វូត )[14]

[13] ម៉ម ចរិយារុធ និង នួន ហេង , សេដ្ឋកិច្ចនយោបាយ ឆ្នាំ ២០១២ ទំព័រ ៦៨

**ក. និយមន័យ**

ស្វូត គឺជាអក្សរកាត់ដែលតំណាងឲ្យពាក្យថា ភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និង កត្តារាំង។ ការវិភាគស្វូត គឺជាឧបករណ៍ធ្វើផែនការយុទ្ធសាស្ត្រមួយ ត្រូវបានដើម្បីពិពណ៌នា និង វាយតម្លៃពីភាពខ្លាំង ភាពខ្សោយក្នុងសហគមន៍ និងវិភាគពីកាលានុវត្តភាព និងកត្តារាំងដែលជា កត្តាខាងក្រៅសហគមន៍ ប៉ុន្តែវាអាចជះឥទ្ធិពលដល់ការអនុវត្តគម្រោង ឬសកម្មភាពរបស់សហ គមន៍ដើម្បីសម្រេចនៅគោលដៅ ។

**ខ. ការកំណត់** SWOT ( **ស្វូត** )

ការកំណត់ស្វូតឲ្យបានត្រឹមត្រូវ គឺមានសារៈសំខាន់ណាស់សម្រាប់ការធ្វើផែនការបន្ទាប់ ដើម្បីសម្រេចគោលដៅ តួយ៉ាងនៅពេលប្រើប្រាស់ស្វូតជាមូលដ្ឋានសម្រាប់ការធ្វើផែនការ ឬ សម្រេចចិត្ត ត្រូវសួរ និងឆ្លើយនិងសំណួរទាំងបួនដូចខាងក្រោម ៖

- តើយើងអាចប្រើប្រាស់ចំណុចខ្លាំងនីមួយៗយ៉ាងដូចម្តេច ?
- តើយើងអាចបញ្ឈប់ភាពខ្សោយនីមួយៗបានយ៉ាងដូចម្តេច ?
- តើយើងអាចទាញយកផលប្រយោជន៍ពីកាលានុវត្តភាពនីមួយៗបានយ៉ាងដូចម្តេច ?
- តើយើងអាចទប់ស្កាត់កត្តាគំរាមកំហែងនីមួយៗបានយ៉ាងដូចម្តេច ?

## ១.៧ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃកត្តាផលិតកម្ម

ប្រសិទ្ធភាពសេដ្ឋកិច្ច[15] គឺជារង្វាស់មួយដែលត្រូវបានប្រើប្រាស់ដើម្បីវាស់ពីការចូលរួមនៃ កត្តាផលិកម្មក្នុងការបង្កើតនូវប្រាក់ចំណូល ដល់ផលិតករ។ ក្នុងនោះដើម្បីកំណត់រកប្រសិទ្ធភាព សេដ្ឋកិច្ច នៃកត្តាផលិតកម្មណាមួយ គឺត្រូវរកផលិតភាពនៃកត្តាផលិកម្មនីមួយៗសិន។ ផលិតភាព នៃកត្តាផលិតកម្មនីមួយៗត្រូវបានកំណត់ដោយអនុគមន៍នៃផលិតកម្មដូចខាងក្រោម៖

$$Q = F ( K ,L )$$

- Q ជាបរិមាណទិន្នផលផលិតកម្មដែលទទួលបាន
- K ជាបរិមាណមូលធនដែលត្រូវបានវិនិយោគក្នុងផលិតកម្ម
- L ជាបរិមាណពលកម្មដែលត្រូវបានយកមកប្រើប្រាស់ក្នុងផលិតកម្ម

[14] Investopedia. http://www.investopedia.com/terms/s/swot.asp.

[15] Quagini L ; Tonichia S. Performance Measurement. 2010 , Page 156

យោងតាមអនុគមន៍ផលិតកម្មខាងលើបង្ហាញអោយឃើញថា ទិន្នផលផលិតកម្ម( Output ) មានភាពប្រែប្រួល អាស្រ័យលើបរិមាណមូលធន និងកម្លាំងពលកម្ម ដែលត្រូវបានប្រើប្រាស់ក្នុងដំណើរការផលិតកម្ម។ ក្នុងនោះផងដែរ កម្រិតនៃការប្រែប្រួល ទិន្នផលផលិតកម្មខ្លាំង រឺខ្សោយ គឺវាអាស្រ័យនឹង ផលិតភាពនៃកត្តាផលិកម្មនីមួយៗផងដែរ។

**ក. ផលិតភាពនៃកត្តាផលិតកម្ម**[16]

ផលិតភាពនៃកត្តាផលិតកម្ម គឺជាបរិមាណទិន្នផលនៃផលិតកម្មដែលកត្តាផលិតកម្ម មួយឯកតាអាចផលិតបានក្នុងពេលវេលាជាក់លាក់ណាមួយ។

– **ផលិតភាពនៃកំលាំងពលកម្ម** ជាបរិមាណទិន្នផលនៃផលិតកម្មដែលកំលាំងពលកម្មមួយឯកតាអាចផលិតបានក្នុងមួយវដ្តផលិតកម្ម រឺពេលកំណត់ណាមួយ។ការគណនាផលិតភាពនៃកំលាំងពលកម្មត្រូវបានកំណត់តាមរូបមន្តដូចខាងក្រោម៖

$$\text{ផលិតភាពនៃកំលាំងពលកម្ម}=\frac{\text{បរិមាណទិន្នផលផលិតកម្ម}}{\text{ចំនួនពលកម្មសរុបដែលបាន}}$$

– **ផលិតភាពនៃមូលធន** ជាបរិមាណទិន្នផលនៃផលិតកម្មដែលមូលធនមួយឯកតា អាចផលិតបានក្នុងពេលកំណត់ណាមួយ។ ផលិតភាពនៃមូលធនអាចគណនាតាមរូបមន្តដូចខាងក្រោម៖

$$\text{ផលិតភាពនៃមូលធន}=\frac{\text{បរិមាណទិន្នផលផលិតកម្ម}}{\text{បរិមាណមូលធនដែលត្រូវបានប្រើប្រាស់}}$$

**ខ.ប្រសិទ្ធភាពសេដ្ឋកិច្ចនៃមូលធនផលិតកម្ម**

ប្រសិទ្ធភាពសេដ្ឋកិច្ចនៃមូលធនផលិតកម្ម គឺជារង្វាស់នៃការចូលរួមរបស់មូលធន ក្នុងការបង្កើតនូវប្រាក់ចំណូលដល់ ផលិតករ ។ ក្នុងនោះប្រសិទ្ធភាពសេដ្ឋកិច្ចនៃមូលធនផលិតកម្មបង្ហាញអោយឃើញថា តើការវិនិយោគ មូលធន ១ ឯកតា នឹងផ្តល់ចំណូលអោយផលិតករវិញប៉ុន្មានឯកតា។ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃមូលធនផលិតកម្មអាចគណនាបានដូចខាងក្រោម៖

ប្រសិទ្ធភាពសេដ្ឋកិច្ចនៃមូលធន=ផលិតភាពនៃមូលធន × តំលៃផលិតផល (ក្នុង ១ ឯកតា)

រឺ

[16] Quagini L ; Tonichia S. Performance Measurement. 2010 , Page 157

$$\text{ប្រសិទ្ធភាពសេដ្ឋកិច្ចនៃមូលធន}=\frac{\text{ប្រាក់ចំណូលសរុបក្នុងមួយវដ្តផលិតកម្ម}}{\text{ប្រាក់ចំណាយលើមូលធនសរុបក្នុងមួយវដ្តផលិតកម្ម}}$$

### គ.ប្រសិទ្ធភាពសេដ្ឋកិច្ចនៃពលកម្ម

ការគណនាប្រសិទ្ធភាពសេដ្ឋកិច្ចនៃពលកម្ម អាចបង្ហាញអោយឃើញថាតើកំលាំងពលកម្មមួយនាក់ អាចផ្តល់ប្រាក់ចំណូលបានប៉ុន្មានក្នុងផលិតកម្មនេះ។

ប្រសិទ្ធភាពសេដ្ឋកិច្ចនៃពលកម្ម=ផលិតភាពនៃពលកម្ម × តំលៃផលិតផល (ក្នុង ១ ឯកតា)

រឺ

$$\text{ប្រសិទ្ធភាពសេដ្ឋកិច្ចនៃកលាំងពលកម្ម}=\frac{\text{ប្រាក់ចំណូលសរុបក្នុងមួយវដ្តផលិតកម្ម}}{\text{ចំនួនពលកម្មសរុប}}$$

### ឃ.មូលធនផលិតកម្ម

មូលធនផលិតកម្មគឺជា មូលធនដែលត្រូវបានវិនិយោគក្នុងកិច្ចដំណើរការផលិតកម្ម។ មូលធនផលិតកម្មត្រូវបានបែងចែកជាពីរគឺៈ

មូលធនថេរ ជាមូលធនដែលតំលៃរបស់ត្រូវបានបញ្ជូនបណ្តើរៗទៅក្នុងផលិតផល ដែលរួមមាន ម៉ាស៊ីន អគារ និងមធ្យោបាយដឹកជញ្ជូនជាដើម។

មូលធនប្រែប្រួល ជាមូលធនដែលតំលៃរបស់វាត្រូវបានបញ្ជូនទៅទាំងស្រុងក្នុងដំណើរការផលិតកម្ម ហើយបរិមាណរបស់វាគឺប្រែប្រួលទៅតាមទិន្នផលផលិតកម្ម។

### ង.ចំណាយ[17]

ក្នុងន័យទូទៅ ចំណាយគឺជាអ្វីៗដែលអ្នកត្រូវលះបង់ដើម្បីទទួលបាននូវអ្វីមួយផ្សេងទៀត។ ក្នុងន័យផលិតកម្ម ចំណាយគឺជាបិរមាណមូលធនដែលអ្នកត្រូវធ្វើការបណ្តាក់ទុនទៅក្នុងដំណើរផលិតកម្ម។

ចំណាយសរុប = ចំណាយថេរ + ចំណាយប្រែប្រួល

TC = TFC + TVC

[17] Ghislain Nono Gueye,Costs of production. 2010

ចំណាយប្រែប្រួល រឺ ចំណាយលើមូលធនប្រែប្រួល គឺជាចំណាយទាំងឡាយណាដែលប្រែប្រួលភ្លាមទៅតាមកម្រិតទិន្នផល ( Output ) ក្នុងដំណើរការផលិតកម្ម។ ប្រសិនបើទិន្នផលផលិតកម្មកើនឡើង នោះចំណាយប្រភេទនេះនឹងកើនឡើង ហើយបើសិនជាទិន្នផលថយចុះ នោះចំណាយប្រភេទនេះនឹងថយចុះដែរ។

– ចំណាយថេរ រឺចំណាយលើមូលធនថេរ គឺជាប្រភេទនៃចំណាយដែលមិនប្រែប្រួល ភ្លាមៗទៅតាមកម្រិតទិន្នផលក្នុងដំណើរការផលិតកម្មនោះទេ ។

**ច.ចំណូល**

ចំណូល ជាប្រាក់ដែលទទួលបានមកវិញការលក់ទិន្នផលនៃផលិតកម្ម។

ចំណូល = ថ្លៃផលិតផលក្នុងមួយឯកតា * បរិមាណផលិតផល

TR = P * Q

.TR: ចំណូលសរុប

. P: ថ្លៃ

.Q: បរិមាណផលិផលសរុប

**ឆ.ប្រាក់ចំណេញ**

ប្រាក់ចំនេញ គឺជាបរិមាណប្រែប្រួលនៃប្រាក់ចំណូល ក្រោយពេលដែលកាត់កងជាមួយនឹងការចំណាយ ។

ប្រាក់ចំណេញ = ប្រាក់ចំណូល - ប្រាក់ចំណាយ

TP = TR - TC

# ជំពូកទី២

# ស្ថានភាពទូទៅនៃសហគមន៍អភិវឌ្ឍន៍កសិកម្មត្នោតកំពង់ស្ពឺ

## ២.១ ស្ថានភាពទូទៅនៃតំបន់សិក្សា

### ២.១.១ ទីតាំងភូមិសាស្ត្រនៃឃុំភ្នំតូច

ឃុំភ្នំតូចជាឃុំមួយក្នុងចំណោមឃុំទាំង១៥នៃស្រុកឧដុង្គ ក្នុងខេត្តកំពង់ស្ពឺ។ ឃុំនេះមានព្រំប្រទល់៖

- ខាងកើតជាប់នឹងឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្ដាល
- ខាងលិចជាប់នឹងឃុំពាំងល្វា
- ខាងជើងជាប់នឹងឃុំដំណាក់រាំងនិង
- ខាងត្បូងជាប់នឹងឃុំសំបូរ ស្រុកសំរោងទង។

ឃុំភ្នំតូចចែកចេញជា១៨ភូមិ មានគ្រួសារសរុប២.៥២០ ប្រជាជនសរុប១៦,១៧០នាក់ ក្នុងនោះស្រីចំនួន៨,៨៩៥នាក់ និងផ្ទៃដីសរុប ៥,៦៥០ ហ.ត។[18]

### ២.១.២ ស្ថានភាពសេដ្ឋកិច្ចប្រជាជនក្នុងឃុំភ្នំតូច

- **ស្ថានភាពមុខរបរប្រជាជន៖** អ្នកធ្វើស្រែ១,៨៧២គ្រួសារ អ្នកឡើងត្នោត២៧៣គ្រួសារ កម្មករសំណង់១០០នាក់ (ស្រី១០នាក់) កម្មករកាត់ដេរ១,០០០នាក់(ស្រី៨២០នាក់) អ្នកលក់ដូរ១១៥គ្រួសារ អ្នករត់ម៉ូតូឌុប១០នាក់ អ្នកសាកអាគុយ៥គ្រួសារ សិប្បកម្មធ្វើដោយដៃ២៥គ្រួសារ ជាងជួសជុលម៉ូតូ១៦គ្រួសារ និងជាងជួសជុលវិទ្យុ ម៉ាញ៉េ ទូរទស្សន៍៥គ្រួសារ។
- **ស្ថានភាពផ្ទះសំបែងរបស់ប្រជាជន៖** ផ្ទះថ្មប្រក់ក្បឿង១០០គ្រួសារ ផ្ទះឈើប្រក់ក្បឿង៧៦៨គ្រួសារ ផ្ទះឈើប្រក់ស័ង្កសី ៥៧៣គ្រួសារ ផ្ទះឈើប្រក់ហ្វីប្រូ ៣៦៧គ្រួសារ ផ្ទះឈើប្រក់ស្លឹក១៩៥គ្រួសារ និងផ្ទះខ្ទម១៨៥គ្រួសារ។

### ២.១.៣ ស្ថានភាពសង្គមកិច្ចក្នុងឃុំភ្នំតូច

នៅក្នុងឃុំភ្នំតូចទាំងមូលមានសាលារៀនចំនួន ៦ខ្នងដែលក្នុងនោះសាលាមតេយ្យចំនួន ២ សាលាបឋមសិក្សាចំនួន ៣ ខ្នង និងអនុវិទ្យាល័យចំនួន ១ ខ្នង សរុបមកមានបន្ទប់រៀនចំនួន ៣៩បន្ទប់។ អត្រានៃភាពក្រីក្រនៅក្នុងឃុំភ្នំតូចក្នុងឆ្នាំ ២០១៤ ស្មើនឹង ២៧,៦០ ភាគរយ។ នៅក្នុង

[18] សាលាឃុំភ្នំតូច. ២០១៥. ស្ថិតិទូទៅ.

ឃុំមានផ្លូវក្រាលគ្រួសក្រហមប្រវែង ១០គីឡូម៉ែត្រ ពីផ្លូវធំទៅកាន់សាលាឃុំ និងមានប្រឡាយទឹកសម្រាប់ស្រោចស្រពចំនួន ៥កន្លែងដែលជាស្រះតូចៗ សម្រាប់ធ្វើកសិកម្ម និងប្រើប្រាស់ប្រចាំថ្ងៃ ។

### ២.១.៤. ស្ថានភាពពលកម្មនៅក្នុងគ្រួសារផលិតករដែលបានចូលរួមក្នុងផលិតកម្ម

ការចូលរួមក្នុងផលិតកម្មរបស់សមាជិកគ្រួសារផលិតករក្នុងផលិតកម្មស្ករត្នោតកំពង់ស្ពឺអាចឆ្លុះបញ្ចាំងឲ្យឃើញអំពីទំហំ និងផលិតភាពនៃផលិកម្មទាំងមូល។

តាមរយៈការសិក្សាស្រាវជ្រាវផ្ទាល់បានបង្ហាញថា គ្រួសារផលិតករដែលមានចំនួនពលកម្មចូលរួមមានចំនួន ២នាក់មានអត្រាខ្ពស់ជាងគេដល់ទៅ ៨៩.៥%។ ដោយឡែកគ្រួសារផលិតករដែលមានពលកម្ម ចូលរួម ៣នាក់វិញមានចំនួនត្រឹមតែ ១០.៥% ភាគរយ ប៉ុណ្ណោះ។ ក្នុងនោះពលកម្មដែលចូលរួមក្នុងផលិតកម្មភាគច្រើនគឺ ប្តីនិងប្រពន្ធ ដែលប្តីជាអ្នកឡើងត្នោត កូរវិតស្ករ រីឯប្រពន្ធវិញជាអ្នករួមក្នុងការដុតភ្លើង លាងសម្អាត សម្ភារៈ រកអុស និងរម្ងាស់ស្ករ។ តារាងខាងក្រោមនេះនឹងបង្ហាញអំពីចំនួនពលកម្មដែលបានចូលរួមក្នុងផលិកម្មរបស់គ្រួសារផលិតករនីមួយៗ។

**តារាងទី 1 ៖ ស្ថានភាពពលកម្មក្នុងគ្រួសារផលិករដែលបានចូលរួមផលិតកម្ម**

| ចំនួនពលកម្មដែលបានចូលរួម | ចំនួនគ្រួសារផលិតករ | ភាគរយ |
|---|---|---|
| ២ | ១៧ | ៨៩.៥ % |
| ៣ | ២ | ១០.៥ % |
| សរុប | ១៩ | ១០០ % |

### ២.១.៥ ប្រភពដើមត្នោតរបស់ផលិតករ

ចំនួនដើមត្នោតដែលស្ថិតនៅតំបន់ភូមិសាស្ត្រ ស្រុកឧដុង្គ ស្រុកសំរោងទង នៃខេត្តកំពង់ស្ពឺ និងស្រុកអង្គស្នួល នៃខេត្តកណ្តាលសរុបមានចំនួន ៨៥៦,៨៨៦ដើម ប៉ុន្តែដើមត្នោតដែលអាចឲ្យផលគឺមានចំនួន ៣៥៤,២៥៤ដើម ហើយចំណែកឯដើមត្នោតដែលមិនទាន់ផ្តល់ផលគឺមាន ចំនួន ៥០២,២៣២ ដើម។ នៅក្នុងការប្រកបរបរឡើងត្នោតនេះ ផលិតករមួយចំនួនប្រើប្រាស់ដើមត្នោតខ្លួនឯងសម្រាប់ធ្វើអាជីវកម្ម និងមួយចំនួនទៀតគឺទទួលបានពីការជួលគេ ហើយផ្សេងពីនេះគឺប្រើប្រាស់ត្នោតខ្លួនឯងផង និងជួលគេផង។ ទន្ទឹមនឹងនេះចំនួនដើមត្នោតនៅក្នុងឃុំភ្នំតូចមានចំនួនសរុបប្រមាណ ៩,៨៥០ដើម ហើយដើមត្នោតដែលអាចយកមកធ្វើអាជីវកម្មបានមានចំនួន

២,៦៣០ដើម។[19] ក្នុងនោះចំនួនសំណាកសមាជិកផលិតករក្នុងឃុំភ្នំតូចដែលយើងយកមកសិក្សាស្រាវជ្រាវ គឺមានចំនួន ១៩ នាក់ ប៉ុណ្ណោះ ដែលផលិករខ្លះ មានដើមត្នោតចន្លោះពី ១ ទៅ ១៥ ដើម ខ្លះទៀត មានចន្លោះពី ១៦ ទៅ ២៥ ដើម និងមួយចំនួនទៀតមាន ពី ២៦ តោ ៣០ ដើម។ ម្យ៉ាងទៀតផលិតករខ្លះមានដើមត្នោតជាកម្មសិទ្ធិរបស់ខ្លួន និងខ្លះទៀតក៏ជួលគេបន្ថែម។ តារាងខាងក្រោមនេះ នឹងបង្ហាញអំពីទិន្នន័យដែលពាក់ព័ន្ធនឹងប្រភពដើមត្នោតខាងលើ៖

**តារាងទី 2 ៖ ចំនួនដើមត្នោតដែលសមាជិកផលិតករប្រើប្រាស់ក្នុងផលិតកម្ម**

| ចំនួនដើមត្នោត | ចំនួនផលិតករ | ភាគរយ |
|---|---|---|
| ចន្លោះពី ១ ទៅ ១៥ដើម | ៤ | ២១.០៥ |
| ចន្លោះពី ១៦ ទៅ ២៥ដើម | ៩ | ៤៧.៣៧ |
| ចន្លោះពី ២៦ ទៅ ៣៥ដើម | ៦ | ៣១.៥៨ |
| សរុប | ១៩ | ១០០ |

## ២.២ សហគមន៍អភិវឌ្ឍន៍កសិកម្មស្ករត្នោតកំពង់ស្ពឺ (ស.អ.ត.ក)[20]

### ២.២.១ រចនាសម្ព័ន្ធគ្រប់គ្រង

សហគមន៍អភិវឌ្ឍន៍កសិកម្មស្ករត្នោតកំពង់ស្ពឺត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយក្រុម រួមមាន ប្រធាន ១ រូប និង អនុប្រធាន ១រូប និងសមាជិកចំនួន ២ រូបផ្សេងទៀត។

សមាសភាពក្រុមប្រឹក្សាភិបាលមានដូចខាងក្រោម៖

- លោក ហុង ហឿន ប្រធាន
- លោក ស៊ុំ អឿន អនុប្រធាន
- លោក ប៉ាង ធា ទីប្រឹក្សា
- លោក សំ ផេង ផ្នែករដ្ឋបាល និងគណនេយ្យ

[19] បទសម្ភាសន៍ផ្ទាល់ជាមួយលោក សំ សារឿន ប្រធានសមាគមលើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ

[20] បទសម្ភាសន៍ផ្ទាល់ជាមួយលោក ហុង ហឿន ប្រធានសហគមន៍អធិវឌ្ឍន៍កសិកម្មត្នោតកំពង់ស្ពឺ

### ២.២.២ តួនាទី និងភារកិច្ចរបស់សហគមន៍

ដើម្បីជាជំនួយផ្នែកហិរញ្ញវត្ថុដល់សមាគមលើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ ដែលជាអង្គភាពមិនស្វែងរកប្រាក់ចំនេញនោះ សហករផលិតស្ករត្នោតក៏ចាប់ផ្តើមប្រមូលផ្តុំគ្នាបង្កើតបានជាសហគមន៍អភិវឌ្ឍន៍កសិកម្មស្ករត្នោតកំពង់ស្ពឺ នៅថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១១។ ហើយការបង្កើតសហគមន៍នេះទៀតសោតគឺ ក្នុងគោលបំណងលើកកម្ពស់ស្ថេរភាពទីផ្សារស្ករត្នោតកំពង់ស្ពឺ និងជីវភាពរបស់ផលិតករអោយកាន់តែប្រសើរឡើង។ សហគមន៍បានជួយសម្រួលដល់ផលិតករជាសមាជិកក្នុងការលក់នូវស្ករត្នោតរបស់ខ្លួន និងទិញសម្ភារៈចូលរួមផលិតកម្ម ប្រកបដោយភាពងាយស្រួល និងប្រសិទ្ធភាព។ ទន្ទឹមនឹងនេះផងដែរ សហគមន៍ដើរតួជាឈ្មួញ ប្រមូលទិញ ស្ករត្នោតកំពង់ស្ពឺដោយផ្ទាល់ពីសមាជិកផលិតករយកមកសម្ងួតបន្ថែម និងលក់បន្តទៅឲ្យក្រុមហ៊ុន ទៅតាមតម្លៃដែលសមាគមបានកំណត់។ សព្វថ្ងៃនេះសហគមន៍មានទីតាំងនៅក្នុងភូមិត្រពាំងអន្ទង ឃុំចាន់សែន ស្រុកឧដុង្គខេត្តកំពង់ស្ពឺ និងមានសមាជិកចំនួន ១១៦នាក់ និងក្រុមហ៊ុនជាដៃគូបញ្ជាទិញចំនួន ៧ក្រុមហ៊ុន។

### ២.២.៣ តំបន់ប្រត្តិបត្តិការរបស់សហគមន៍

សហគមន៍ធ្វើប្រតិបត្តិការលើ តំបន់ភូមិសាស្ត្រនៃទំនិញសម្គាល់ភូមិសាស្ត្រ "ស្ករត្នោតកំពង់ស្ពឺ"ដែលមានចំនួន ៣ ស្រុក គឺ ស្រុក ឧត្តុង្គ និងស្រុក សំរោងទង នៃខេត្តកំពង់ស្ពឺ និងស្រុកអង្គស្នួល នៃខេត្តកណ្តាល។ តំបន់ភូមិសាស្ត្រគឺជាតំបន់គ្រោងទុកមួយដែលត្រូវបានកំណត់ដោយអាជ្ញាធរអប្បារា តាមរយៈការសិក្សាលើលក្ខខ័ណ្ឌមួយចំនួនរួមមាន កត្តាអាកាសធាតុ ប្រភេទដី និងដង់ស៊ីតេ រុក្ខជាតិដែលត្រូវបានដាំដុះ។ ជាក់ស្តែង អាស្រ័យដោយពពួកទឹកភ្លៀងដែលច្រើនតែមានតិចតួច និងអាស្រ័យសណ្ឋានដីនៅតំបន់ ៣ ស្រុកនោះ សំបូរដោយខ្សាច់នៅស្រទាប់លើ និងមានក្រួសនៅស្រទាប់ជ្រៅធ្វើឱ្យទឹកជ្រាបបានល្អ ទើបទឹកត្នោតនៅទីនោះមានរសជាតិផ្អែមឈ្ងុយឆ្ងាញ់ពិសេសខុសពីតំបន់ដ៏ទៃ។ ខេត្តកំពង់ស្ពឺ ដែលមានស្រុកសរុបចំនួន ៨ គឺមានតែ ២ស្រុកប៉ុណ្ណោះ ដែលត្រូវបានចាត់ទុកជាតំបន់នៃការប្រមូលផល នូវស្ករត្នោតកំពង់ស្ពឺ ក្រោមស្លាកសញ្ញាទំនិញសម្គាល់ភូមិសាស្ត្រ និងបូកបន្ថែមនូវ ស្រុកអង្គស្នួល នៃខេត្តកណ្តាលមួយទៀត។

### ២.២.៤ ធនធានហិរញ្ញវត្ថុ

ដើម្បីបន្តការអភិវឌ្ឍន៍សហគមន៍អោយកាន់តែមានភាពរឹងមាំ ក្នុងការលើកកម្ពស់ដល់ជីវភាពផលិតករជាសមាជិក ក៏ដូចជាផ្គត់ផ្គង់ដល់ដំណើរការសកម្មភាពរបស់ខ្លួន និងរបស់សមាគម សហគមន៍គឺត្រូវពឹងផ្អែកលើប្រភពហិរញ្ញវត្ថុ ៤ យ៉ាងសំខាន់ៗរួមមានៈ

- ការលក់ហ៊ុន ទៅអោយសហាករដែលជាសមាជិកសហាគមន៍ ដែលក្នុងមួយហ៊ុន មានតំលៃ ១០,០០០៛ ។ ជាក់ស្តែងមកដល់បច្ចុប្បន្ន គឺបានលក់ ចំនួន ៦៣១ហ៊ុនហើយ។ សមាជិកដែលបានទិញហ៊ុននេះ នឹងត្រូវទទួលបាន ភាគលាភជារៀងរាល់ ១ ឆ្នាំម្តង ដែលចំនួនភាគលាភនឹងត្រូវបានប្រកាសដោយក្រុមប្រឹក្សាភិបាលរបស់សហាគមន៍។
- ប្រាក់ចំណេញដែលបានមកពីការប្រមូលទិញលក់ស្ករត្នោតពីផលិតករទៅអោយក្រុមហ៊ុន។
- ក្រុមហ៊ុនជាអ្នកបញ្ជាទិញ តែងតែផ្តល់កម្រៃបន្ថែមចំនួន ១០០$ ក្នុង១តោនមកដើម្បីដាក់ចូលមូលនិធិរបស់សហាគមន៍ ក្នុងការបង្កើនដើមទុនរបស់ខ្លួន ក៏ដូចជាជួយដល់សមាជិក ផលិតករដែលបានជួបនូវគ្រោះថ្នាក់ជាយថាហេតុណាមួយ។
- ការផ្តល់ជាជំនួយផ្នែកហិរញ្ញវត្ថុពីក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត។

## ២.៣.ខ្សែចង្វាក់ផលិតកម្មស្ករត្នោតកំពង់ស្ពឺ[21]

### ២.៣.១ តំបន់ភូមិសាស្ត្រ និងភស្តុតាងបញ្ជាក់ពីប្រភព

#### ក. តំបន់ភូមិសាស្ត្រ

ដើមត្នោតដែលអាចផ្តល់ទឹកត្នោតសម្រាប់តំបន់ផលិតកម្ម " **ស្ករត្នោតកំពង់ស្ពឺ** " ត្រូវស្ថិតនៅក្នុងស្រុកទាំងបីដូចខាងជា៖ ស្រុកឧដុង្គ និងស្រុកសំរោងទង នៃខេត្តកំពង់ ស្ពឺ និងស្រុកអង្គស្នួល នៃខេត្តកណ្តាល។ ហើយត្រូវស្ថិតនៅលើប្រភេទ ដីខ្សាច់ដែលមានជម្រៅយ៉ាងតិច ០.៨ ម៉ែត្រ នៅបាតក្រោមមានគ្រួស និងជាប្រភេទដីស្រស់ទឹកល្អ។

#### ខ. ភស្តុតាងបញ្ជាក់ពីប្រភព

ដើម្បីទទួលបានសិទ្ធិក្នុងការផលិត និងលក់ " ស្ករត្នោតកំពង់ស្ពឺ " ប្រតិបត្តិករត្រូវចុះបញ្ជីនៅ " សមាគមលើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ " ដើម្បីក្លាយជាសមាជិក។ រាល់ប្រតិបត្តិករទាំងអស់ត្រូវប្រកាសបរិមាណផលិតផលដែលបានផលិត និងចុះបញ្ជីផលិតផលដែលបានលក់ដូរ។ ប្រព័ន្ធស្វែងរកទឹកដានត្រូវបានបង្កើតឡើង ដើម្បីតាមដានផលិតផលតាំងពីផលិតរហូតដល់លក់នៅលើទីផ្សារ។

### ២.៣.២ ខួបនៃផលិតកម្មស្ករត្នោតកំពង់ស្ពឺ

រដូវកាលនៃផលិតកម្មស្ករត្នោតកំពង់ស្ពឺឬហៅម្យ៉ាងទៀតថាស្ករត្នោតសម្គាល់ភូមិសាស្ត្រ

[21] សមាគមលើកកម្ពស់ស្ករត្នោតកពង់ស្ពឺ ,សៀវភៅបន្ទុកស្ករត្នោតកំពង់ស្ពឺ ,២០០៩

ត្រូវបានកំណត់ទៅតាមសៀវភៅបន្ទុកយ៉ាងជាក់លាក់ គឺចាប់ផ្ដើមពីដើមខែធ្នូ និងបញ្ចប់នៅចុងខែមេសា ។ ប៉ុន្តែជាក់ស្ដែងវិញ លទ្ធភាពចេញផ្កាដែលអាចប្រមូលផលបានរបស់ រុក្ខជាតិត្នោតគឺមានភាពខុសៗគ្នា ទើបបណ្ដាលអោយ ការចាប់ផ្ដើមធ្វើផលិតកម្មស្ករត្នោតកំពង់ស្ពឺ និងបរិមាណផលិតស្ករត្នោតរបស់ផលិតករក៏មានភាពខុសគ្នាដែរ។ ការប្រមូលផលទឹកត្នោតគឺអាចធ្វើបានយ៉ាងច្រើនពីរដង ក្នុងរយៈពេលមួយថ្ងៃ។ ការធ្វើបែបនេះគឺដើម្បីរក្សាទុកផ្កាត្នោតមួយចំនួនសម្រាប់ចេញផ្លែ និងដើម្បីធានា អោយបាននូវនិរន្តរភាពរបស់ដើមត្នោត ។ អាចប្រើប្រាស់ផ្កាត្នោតបានយ៉ាងច្រើនគឺ ២៥ ភាគរយនៃផ្កាត្នោតសរុប ដើម្បីប្រមូល យកទឹកត្នោត ធ្វើបែបនេះគឺដើម្បីឲ្យត្នោតមានផ្លែ និងរក្សាបាននូវនិរន្តរភាពត្នោត។

### ២.៣.៣ ប្រភេទស្ករ

នៅក្នុងសមាគមគេបានបែងចែកស្ករជាពីរប្រភេទ **ប្រភេទទីមួយគឺស្ករសរីរាង្គ** និង**ប្រភេទទីពីរគឺស្ករសម្គាល់ភូមិសាស្ត្រ** ( GI ) ហើយចំណែកឯភាពខុសគ្នារវាងស្ករសរីរាង្គ និងស្ករ GI គឺមានលក្ខណៈដូចតទៅ៖ ដើមត្នោតដែលត្រូវយកមកធ្វើជាស្ករសរីរាង្គមានលក្ខណៈ ១.ដើមត្នោតដុះនៅលើដីទួល ២.ដើមត្នោតនៅក្នុងភូមិ ៣.ដើមត្នោតដែលស្ថិតនៅឆ្ងាយពីទីកន្លែងដាំដុះដំណាំផ្សេងៗ (ដំណាំស្រូវ បន្លែ និងផ្លែឈើ ។ ល ។ ) ដែលមានប្រើប្រាស់នូវសារធាតុគីមី ។ ចម្ងាយដើមត្នោតចន្លោះយ៉ាងតិច ៣ម៉ែត្រ រាល់ដើមត្នោតសរីរាង្គទាំងអស់ និងត្រូវដាក់លេខកូដសម្គាល់ដោយលេខកូដនោះមានរួមបញ្ចូលនូវលេខកូដភូមិ លេខកូដរបស់ផលិតករ និងលេខរៀងដើមត្នោត។ មានតំបន់ទ្រនាប់ការពារការឆ្លងនូវសារធាតុផ្សេងៗ ដែលមិនស្របតាមស្តង់ដារសរីរាង្គរបស់អេកូសែក និងសហភាពអឺរ៉ុប។ រីឯដើមត្នោតដែលត្រូវយកមកធ្វើជាស្ករជីអាយ (GI) មានលក្ខណៈ ១.ត្រូវតែស្ថិតនៅក្នុងភូមិទាំងបីដែលបានចុះជីអាយ ២.ត្រូវស្របតាមសៀវភៅបន្ទុក ៣.លើកលែងតែចំណុចទាំងបីខាងលើរបស់ស្ករសរីរាង្គហើយចំណែកឯខ្សែចង្វាក់ផលិតកម្មវិញគឺដូចគ្នាទាំងអស់

**តារាងទី 3 ៖ ការពិពណ៌នាពីលក្ខណៈ " ស្ករត្នោតកំពង់ស្ពឺ "**

| ប្រភេទ | ស្ករម្សៅ | ស្ករសាច់ | ស្ករផែន |
|---|---|---|---|
| **វាយនភាព** | .មិនស្អិតជាប់ដៃ | .ស្អិតតិច ទៅមិនស្អិត | .ក្រាមមធ្យមទៅច្រើន |
| | .មានទំហំគ្រាប់តូចជាង ឬស្មើ១,៥ ម.ម | .មានក្រាមមធ្យមទៅច្រើន | .មានជាប់ម្សៅជាប់តិចៗ |
| | .ស្ងួតទៅៗ ល្អ | | .ស្ងួតទៅស្ងួតខ្លាំង |

| | | | |
|---|---|---|---|
| **ពណ៌** | .សាច់ល្ពៅ G3-G5 | .សាច់ល្ពៅ G1-G5 | .សាច់ល្ពៅG3-G7 |
| **សក្លិន** | .មានក្លិនដមស្ករត្នោត | | |
| | .មិនត្រូវមានក្លិន -ផ្សិត -ខ្លោច | | |
| **រសជាតិ** | .ផ្អែមខ្លាំង<br>.រសជាតិស្ករត្នោត<br>.អាចមានរសជាតិជូ និងចត់តិចៗ | .ផ្អែមមធ្យមទៅផ្អែមខ្លាំង<br>.អាចមានរសជាតិជូនិងចត់តិចៗ<br>.រសជាតិដមត្នោតពីមធ្យមទៅខ្លាំង | .ផ្អែមមធ្យមទៅខ្លាំង<br>.រសជាតិស្ករត្នោតមធ្យមទៅខ្លាំង<br>.អាចមានរសជាតិជូរនិងចត់<br>តិចៗ |
| **លក្ខណៈគីមី** | .ស្ករ>៩៥%<br>.PH=៤.៥-៦.៥<br>.សកម្មភាពទឹក≤0.៨៥ | .ស្ករ=៨៥%-៩៥%<br>.PH=៤.៥-៦.៥<br>.សកម្មភាពទឹក≤0.៨ | .ស្ករ=៥0%-៧0%<br>.PH=៣.៥-៦.៥<br>.សកម្មភាពទឹក≤0.៨៥ |

**២.៣.៤ បច្ចេកទេសផលិតកម្ម**

**២.៣.៤.១ ដំណើរការនៃការប្រមូលផលទឹកត្នោត**

ផ្កាត្នោត អាចប្រមូលបានទាំងផ្កាញី និងផ្កាឈ្មោល ការប្រមូលផលទឹកត្នោតធ្វើឡើងនៅរដូវប្រាំង គឺចាប់ពីពាក់កណ្តាលខែធ្នូ ហើយចប់នៅខែឧសភា ។ ក្រោយមកកសិករ ឡើងដើមត្នោតដោយនាំយកនូវត្របៀតទៅតាមប្រភេទដើមត្នោត។ ចំពោះដើមត្នោតដើមត្នោតញីនៅពេលផ្កា លូតលាស់ធំបន្តិចហើយនៅពេលនោះក្តិបផ្កាលេចរូបរាង នៅចំកណ្តាល កសិករចាប់ផ្តើមកៀបបំបែកយ៉ាងស្រាល ហើយកៀបទងផ្កាពីចុងរហូតដល់គល់។ ការងារនេះគេត្រូវប្រព្រឹត្តទៅក្នុងរយៈពេលពី ៥ ទៅ ៧ ថ្ងៃ ហើយនៅថ្ងៃទី ៨ គេត្រូវចិតចុងផ្កាបន្តិច ដើម្បីអោយទឹកត្នោតស្រក់ចេញ ហើយគេនៅតែត្រដុសអង្អែលយ៉ាងខ្លាំង ដើម្បីកុំអោយក្តិបផ្លែឡើងធំបាន គេធ្វើរបៀបនេះរហូតដល់១០ថ្ងៃ។ ក្នុងការប្រមូលទឹកត្នោតពីរដងក្នុងមួយថ្ងៃ អ្នកឡើងត្នោតត្រូវតែឡើងទៅចិតដោយចិតបន្តិចប៉ុណ្ណោះគឺ ៥០ ម.ម ហើយពត់អោយចូលក្នុងបំពង់ដែលគេចងនឹងធាង ត្នោត។ ក្នុងមួយដើមត្នោតយើងអាចត្រងទឹកត្នោតពី ៥ ទៅ ៦ បំពង់ ហើយក្នុងមួយបំពង់មានផ្កាពី ២ ទៅ ៣ ទង។ ចំណែកឯការប្រមូលយកទឹកត្នោតវិញគឺពីរដងក្នុងមួយថ្ងៃ នៅពេលព្រឹកចាប់ផ្តើមពីម៉ោង ៥ និងបញ្ចប់ម៉ោង១២ ឬម៉ោង១ ហើយនៅពេលល្ងាចវិញចាប់ផ្តើមពីម៉ោង ១ និងបញ្ចប់នៅម៉ោង ៧

ឬ ម៉ោង៨។ ហើយគេដឹងថាផលិតភាពនៃរុក្ខជាតិនេះឡើងដល់កម្រិត ខ្ពស់បំផុត គឺនៅពេលដែលដើមត្នោតមានអាយុកាលពី ២៥ ទៅ ៣០ ឆ្នាំឡើងទៅហើយបន្តអោយ ផលខ្ពស់បែបនេះក្នុងរយៈពេលប្រ៣០ឆ្នាំ នៃអាជីវកម្មដើមត្នោតដែលដុះលូតលាស់ល្អ គ្មានសត្វល្អិតបំផ្លាញ និងជម្ងឺរាតត្បាត។



**រូបភាពទី 1 ៖ការប្រមូលផលទឹកត្នោត**

### ២.៣.៤.២ ការកៀប និងចិតផ្កា

**ផ្កាញី:** ចំពោះផ្កាញីនៅពេលដើមត្នោតចេញផ្កាបែកចេញខ្លួកពេលនោះ គេចាប់ផ្ដើមកៀបចាប់ពី ៥ ទៅ ៧ថ្ងៃទើបចាប់ផ្ដើមកាត់មុខ ដោយប្រើឃ្នាបមូល ចំណែកឯការចិតផ្កាវិញគឺចិតជាចំណិតស្ដើងៗទៅលើ ផ្កាដែលបានកៀបរួចដោយប្រើប្រាស់កាំបិតមុតល្អ ហើយដើមត្នោតញីមួយដើមអាចឲ្យផលទិន្នផលជាទឹក៨០០លីត្រក្នុងមួយឆ្នាំ។ ហើយក្នុងរយៈពេលនោះយើងត្រូវសង្កេតទៅលើផ្កាសិនបើចិតហើយ ទឹកត្នោតចេញពុំសូវល្អនោះ យើងត្រូវត្រាំផ្កាក្នុងទឹកចំនួនពីរថ្ងៃ និងទុកចោលមួយថ្ងៃរួចហើយចាប់ ផ្ដើមចិតម្ដងទៀត។




**រូបភាពទី 2 ៖ការគាប និងចិតត្រងផ្កាត្នោតញី**

**ផ្កាឈ្មោល:** ដោយឡែកដើមត្នោតឈ្មោលវិញពេលផ្កាបែកចេញពីខ្លក ហើយគេសង្កេតឃើញមានលំអងពណ៌លឿង គេចាប់ផ្តើមគាបក្នុងរយៈពេលពី ៥ ទៅ ៧ថ្ងៃ ទើបគេចាប់ផ្តើម ចិតដោយប្រើឃ្នាបសំប៉ែត ហើយក្នុងរយៈពេលនោះយើងត្រូវសង្កេតទៅលើផ្កាសិនបើចិតហើយ ទឹកត្នោត ចេញពុំសូវល្អនោះ យើងត្រូវត្រាំផ្កាក្នុងទឹកចំនួនពីរថ្ងៃ និងទុកចោលមួយថ្ងៃរួចហើយចាប់ផ្តើមចិតម្តងទៀត។



**រូបភាពទី 3 ៖ការគាប និងចិតត្រងផ្កាត្នោតឈ្មោល**

### ២.៣.៤.៣ ការស្រុះ ឬអប់បំពង់

បំពង់ក្រោយពីការប្រើប្រាស់ហើយត្រូវតែលាងសម្អាត ឬស្រុះជាមួយនឹងទឹកក្តៅ ជារៀងរាល់ពេល ដើម្បីកុំឲ្យមានជាតិជូរបាយហើយត្រូវសំដិលឲ្យស្ងួត។ មុនពេលយកបំពង់ទៅត្រងទឹកត្នោតត្រូវយកបំពង់ទៅអប់នឹងចង្ក្រានអប់ ដោយប្រើប្រាស់ស្លឹកត្នោតសម្រាប់ដុតកាន់តែប្រសើរ។ ការដុតអប់បំពង់នេះក្នុងគោលបំណងសម្លាប់មេរោគ និងធ្វើអោយទឹកត្នោតមានក្លិនឡើងឈ្ងុយឈ្ងប់ ។



**រូបភាពទី 4 ៖ការស្រុះបំពង់ទឹកត្នោតមុខពេលយកទៅត្រងទឹកត្នោត**

### ២.៣.៤.៤ ការដាក់ពពេល

ពពេលជារុក្ខជាតិម្យ៉ាងដែលចាំបាច់បំផុតក្នុងការដាក់ក្នុងទឹកត្នោត ដែលវាធ្វើឲ្យ ក្រជូរ ហើយថ្លាផ្តល់សារធាតុផ្អែមបានយូរ។ ពពេលត្រូវបានគេដាក់ក្នុងបំពង់ឬស្សីដែលបានអប់រួច សម្រាប់យកទៅត្រងទឹកត្នោតហើយវាជំនួយក្នុងការធ្វើអោយស្ករសល្អទៀតផង។ ជាទូទៅពពេល ត្រូវបានគេប្រើប្រាស់ក្នុងសមាមាត្រ ២០ក្រាមក្នុងទឹកត្នោតមួយលីត្រ។ លក្ខណៈរបស់ពពេលមាន ច្រើនប្រភេទ ប៉ុន្តែប្រជាកសិករភាគច្រើនជ្រើសរើសពពេលដែលដុះនៅប្រភពព្រៃល្បោះ ឬនៅ តាមទីទួលខ្ពស់ ដែលគេនិយមហៅថា ពពេលខ្សាច់ និងធ្វើអោយស្ករក្រាមល្អ ។ ការប្រើប្រាស់ ពពេលគឺធ្វើឡើងទៅតាមទម្លាប់របស់អ្នកប្រើ គេអាចប្រើប្រាស់គ្រប់ផ្នែកទាំងអស់នៃដើម ប៉ុន្តែភាគ ច្រើនគេប្រើប្រាស់ផ្នែកខាងគល់ ឬឫសដែលចត់ខ្លាំងជាងធ្វើអោយស្ករសហើយមានគុណភាព ល្អ។



**រូបភាពទី 5 ៖រុក្ខជាតិពពេលដែលប្រជាកសិករតែងតែយកមកដាក់ក្នុងទឹកត្នោត**

### ២.៣.៤.៥ ការរម្ងាស់ទឹកត្នោត

ចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩ ផលិតករត្រូវធ្វើការរម្ងាស់ទឹកត្នោតដោយប្រើប្រាស់ចង្ក្រាន កែលំអរ ( ជាចង្ក្រានដែលប្រែប្រាស់អុសតិចការពារផ្សែង និងកំទេចផ្សេងៗមិនឲ្យធ្លាក់ចូលក្នុងខ្ទះ រម្ងាស់ ស្ករត្នោត ជួយឲ្យស្ករត្នោតមានពណ៌ល្អ ព្រោះខ្ទះមិនខ្លោចមាត់នៅពេលរម្ងាស់)។ ទីកន្លែង រម្ងាស់ ត្រូវរៀបចំរោងមានប្រក់ដំបូលពីស្លឹក ឬសង្ក័សី និងមានអនាម័យល្អ (បោសកំទេចស្លឹកឈើ ចេញ មិនមានគំនរលាមកនៅក្បែរ ។ ល ។ ) ដើម្បីដុតរម្ងាស់ទឹកត្នោតផលិតករអាចប្រើប្រាស់៖

ឈើ អង្កាម អាចម៍រណា និងកំទេចកំទីរុក្ខជាតិ ក្នុងករណីដែលយើងប្រើប្រាស់ឧស្ម័ន(ហ្គាស)ដើម្បីរម្ងាស់ស្ករត្នោតយើងអាចប្រើប្រាស់ ចង្ក្រាន ធម្មតា ហើយនៅពេលរម្ងាស់ផលិតករមិនត្រូវបន្ថែមអ្វីទាំងអស់គឺគ្រាន់តែដងពពុះចេញពីខ្ទះតែប៉ុណ្ណោះ។



រូបភាពទី 6 ៖ការដុតរម្ងាស់ទឹកត្នោត

## ២.៣.៤.៦ របៀបផលិតស្ករសាច់

បន្ទាប់ពីការរម្ងាស់ទឹកត្នោតឆ្អិន ( ស្ករលោត ) រួចផលិតករពីរនាក់ត្រូវលើកខ្ទះស្ករចេញពីចង្ក្រានដាក់នៅកន្លែងមានលំនឹង និងងាយស្រួលក្នុងការកូរ ឬវិត រួចផលិតករម្នាក់ចាប់ផ្តើមកូរដោយឈើខ្នូរ តាមជំនាញរបស់ពួកគាត់ ការកូររបៀបនេះត្រូវប្រុងប្រយ័ត្នស្ករខ្ទាតលើបណ្តាលអោយរលោកបាន។ ប្រសិនបើជាមិនមានកំលាំងគ្រប់គ្រាន់ទេ ម្នាក់ទៀតមកកូរជំនួសរហូតដល់ឡើងបែកសាច់ស្ករ-សល្អ(រយៈពេលប្រហែល១៥នាទី)។ បន្ទាប់មកផលិតករអាចចាក់ស្ករនោះចូលក្នុងពាង ធុង ពីដុងជ័រ ចាន់ តាមការងាយស្រួល និងតាមទម្ងន់ផ្ទុករបស់ទាំងនោះ។



រូបភាពទី 7 ៖ការវិតទឹកត្នោតដើម្បីទទួលបានជាស្ករសាច់

### ២.៣.៤.៧ របៀបផលិតស្ករម្សៅ

ប្រសិនបើយើងចង់បានស្ករម្សៅ ត្រូវអនុវត្តវិធីក្លូរនេះបន្តទៀត រហូតសាច់ស្ករបែកចេញគ្នាជាគ្រាប់ៗ នោះយើងនឹងទទួលបានស្ករម្សៅ ដែលមានគុណភាពល្អ។ បន្ទាប់មកផលិតករយកកញ្ច្រែងមកចូកកំទេចស្ករដាក់ក្នុងកញ្ច្រែង រែងដាក់ទៅក្នុងចានដែកធ្វើរបៀបនេះរហូតដល់អស់ស្ករ ពីក្នុងខ្ទះ។ ក្រោយពេលបានកំទេចស្ករហើយផលិតករយកកំទេចស្ករនោះទៅហាលថ្ងៃផ្ទាល់នឹងពន្លឺ ព្រះអាទិត្យ ដើម្បីបានស្ករស្ងួតនិងហុយ។ ពេលនោះពួកគាត់អាចច្រកស្ករហុយដាក់នៅក្នុងការ៉ុង ទុកដាក់បាន។



រូបភាពទី 8 ៖របៀបផលិតជាស្ករម្សៅ

**២.៣.៤.៨ របៀបផលិតស្ករផែន**

ការផលិតស្ករផែនដូចគ្នានឹងស្ករសាច់ដែរ ខុសប្លែកគ្នាតែស្ករផែនផលិតករយកស្ករដែលរិត ឬកូរហើយចាក់ចូលក្នុងពុម្ពធ្វើពីស្លឹកត្នោតតាមទំហំផ្សេងៗគ្នាដែលគេនិយមចូលចិត្ត។ ពេលដែលស្ករស្ងួតហើយផលិតករដាក់តម្រួតគ្នាជាស្រោក់ធ្វើពីស្លឹកត្នោតចំនួន១០ផែន។



**រូបភាពទី 9 ៖របៀបផលិតស្ករផែន**

**តារាងទី 4 ៖ រយៈពេល រម្ងាស់និងកូរ ឬ រិត**

| ប្រភេទ | រយៈពេលរម្ងាស់ | រយៈពេលកូរឬរិត |
|---|---|---|
| ស្ករសាច់ ឬស្ករពាង | ៣ម៉ោង | ១៥នាទី |
| ស្ករម្សៅ ឬស្ករហុយ | ៣ម៉ោង១៥នាទី | ៣០នាទី |
| ស្ករផែន ( ស្ករដុំ ) | ៣ម៉ោង១៥នាទី | ២០នាទី |

នៅខណៈពេលដែលការរម្ងាស់ ឈានមកដល់ដំណាក់កាលកំណត់មួយ ត្រូវលើកខ្ទះចេញពីចង្ក្រាន និងចាប់ផ្តើមកូរ និងរិតដើម្បីអោយស្ករមានពណ៌ល្អ៖

– ស្ករម្សៅឬស្ករហុយ រិតដោយអន្ទោក និងខ្នូរ ( ធ្វើពីឈើ ឬអ៊ីណុក )

– ស្ករប្រភេទផ្សេងទៀតវិតដោយអន្ទោក ឬខ្នូរ

សម្រាប់ដើមត្នោតមួយដើម អាចផលិតស្ករត្នោតកំពង់ស្ពឺប្រភេទស្ករពាង ឬស្ករសាច់យ៉ាងច្រើនបំផុត៧០ ទៅ៨០ គីឡូក្រាម ឬស្ករប្រភេទផ្សេងទៀតដែលសមមូលនឹងស្ករពាងឬស្ករសាច់ក្នុងមួយរដូវ។



**រូបភាពទី 10 ៖របៀបនៃការវិតស្ករ**

## ២.៣.៤.៩ ការទុកដាក់ ( ស្តុកស្ករ )

សម្ភារៈដែលអាចប្រើប្រាស់សម្រាប់ស្តុកស្ករមុនពេលវេចខ្ចប់មានដូចជា៖ ពាងដី ឬខាប់ (ដី) ឬ ធុងជ័រ ឬថង់ជ័រប្រើប្រាស់សម្រាប់ដាក់អាហារ។ ត្រូវទុកស្ករដែលកែច្នៃរួចនៅក្នុងថង់ និងច្រកក្នុងការ៉ុងថ្មីស្អាត ដោយនៅលើការ៉ុងត្រូវមានកត់លេខកូដផលិតករ បរិមាណស្ករត្នោត និងថ្ងៃខែផលិត ទីកន្លែងទុកដាក់ត្រូវតែជាទីកន្លែងដែលស្ងួតល្អ ទីកន្លែងស្អាត និងទុកអោយឆ្ងាយពីពន្លឺថ្ងៃ ជាទីកន្លែងដែលមានអនាម័យស្អាតជានិច្ច។

**តារាងទី 5 ៖ រយៈពេលស្តុកទុកស្ករត្នោត**

| ប្រភេទ | ស្ករម្សៅ | ស្ករសាច់ | ស្ករផែន |
|---|---|---|---|
| រយៈពេលស្តុកបណ្តោះអាសន្ន | ៣ខែ | ៣ខែ | ៣ខែ |
| រយៈពេលប្រើប្រាស់ | ៣ឆ្នាំ | ១ឆ្នាំ | ១ឆ្នាំ |

## ២.៣.៤.១០ ការវេចខ្ចប់ស្ករត្នោតកំពង់ស្ពឺ

ចំពោះសមាគមផ្ទាល់ ពុំទាន់មានលទ្ធភាពវេចខ្ចប់ស្ករត្នោតដោយខ្លួនឯងនៅឡើយទេ ប៉ុន្តែតម្រូវអោយឈ្មួញប្រើឈ្មោះ " ស្ករត្នោតកំពង់ស្ពឺ "។

**ចំពោះស្លាកយីហោស្ករត្នោតកំពង់ស្ពឺនៅលើកញ្ចប់រួមមានដូចជា៖**

– ស្លាកសញ្ញា ឬលេខកូដផលិតផលសម្គាល់ភូមិសាស្ត្រប្រទេសកម្ពុជា។

– ស្លាកសញ្ញាផលិតផលសម្គាល់ភូមិសាស្ត្រ " ស្ករត្នោតកំពង់ស្ពឺ " និងប្រភេទស្ករត្នោតកំពង់ស្ពឺ

– ស្លាកសញ្ញាអាចរួមបញ្ចូលលេខកូដ ដែលជាជំនួយសម្រាប់ធ្វើអោយប្រាកដដល់ការ ស្វែងរកទីកដានជាក់ស្តែងបច្ចុប្បន្ននេះ តាមការសិក្សាផលិតផលស្ករត្នោតកំពង់ស្ពឺ។

ក្នុងការវេចខ្ចប់ស្ករ អ្នកវេចខ្ចប់មិនត្រូវប្រើប្រាស់សម្ភារៈ ដែលអាចប៉ះពាល់ដល់គុណភាពស្ករនោះទេ។ ដោយស្របនឹងលក្ខខ័ណ្ឌមួយចំនួនដូចជា៖ ការប្រើប្រាស់សម្ភារៈវេចខ្ចប់ណាដែលគ្មាន អន្តរកម្មជាមួយនិងស្ករត្នោតអាចរក្សាគុណភាពបានយូរ មិនជ្រាបខ្យល់ និងការវេចខ្ចប់ដោយគិតលើផលប៉ះពាល់បរិស្ថាន។ បច្ចេកទេសនៃការវេចខ្ចប់របស់ឈ្មួញមានលក្ខណៈខុសៗគ្នាទៅតាម បរិមាណនៃការវេចខ្ចប់សំបក និងប្រភេទស្ករ។

. **ការវេចខ្ចប់របស់សហគ្រាសសេដាក ( SAHAKKREAS CEDAC ):** សហគ្រាសសេដាកបាន និងកំពុងទិញស្ករត្នោតកំពង់ស្ពឺ ២ ប្រភេទគឺស្ករសាច់ និងស្ករម្សៅ។ ហើយចំពោះស្ករសាច់សហគ្រាសវេចខ្ចប់ក្នុងកែវជ័រ និងច្រកថង់ផ្លាស្ទិច មួយជាន់ពីខាងក្រៅដោយចែកជាបីប្រភេទគឺ ប្រភេទទី១ទម្ងន់ ១/២ គីឡូក្រាម ប្រភេទទី២ ទម្ងន់៥ គីឡូក្រាម និងប្រភេទទីបី ទម្ងន់ ១០ គីឡូក្រាម។ រីឯស្ករម្សៅវិញ គឺច្រកក្នុងថង់ផ្លាស្ទិចដែលមិនជ្រាបខ្យល់ និងមានទម្ងន់ ១/២ គីឡូក្រាម។

. **ការវេចខ្ចប់របស់ក្រុមហ៊ុនខន់ហ្វីរេល ( CONFIREL ) :** ក្រុមហ៊ុនទិញតែប្រភេទស្ករម្សៅតែមួយមុខប៉ុណ្ណោះ ហើយការវេចខ្ចប់មានបីប្រភេទ ទីមួយគឺប្រភេទជាស្នុកដែលធ្វើពីត្នោត ហើយក្នុងនោះបានចែកចេញជាពីរទម្ងន់ទៀតគឺ ៥០០ក្រាម និង ១០០០ក្រាម ប្រភេទទី២គឺជាប្រអប់ហើយក្នុងមួយប្រអប់មានចំនួន ២៥កញ្ចប់ ហើយមួយកញ្ចប់មានទម្ងន់ ៥ក្រាម និងប្រភេទទី៣ជាប្រភេទកញ្ចប់ធំហើយក្នុងមួយកញ្ចប់ធំមាន៥០កញ្ចប់តូចដោយមួយកញ្ចប់នោះមានទម្ងន់ ៥ក្រាម ដោយច្រកក្នុងថង់ផ្លាស្ទិចដែលមិនជ្រាបខ្យល់ ។

. **ការវេចខ្ចប់របស់ក្រុមហ៊ុនសុវណ្ណៈ៖** ខាងក្រុមហ៊ុនទិញតែប្រភេទស្ករម្សៅ តែមួយមុខប៉ុណ្ណោះ ហើយចំការវេចខ្ចប់វិញគឺមាន២ប្រភេទ ប្រភេទទី១គឺជាកញ្ចប់ ដែលប្រភេទជាកញ្ចប់នោះមាន៣ទម្ងន់ ដូចជា៖ ៥០០ក្រាម និង ២០០ក្រាម និងប្រភេទទី២គឺជាកាបូបធ្វើពីស្លឹកត្នោតដែលមានទម្ងន់១៥០ក្រាម ដែលកាបូបស្លឹកត្នោតនោះផលិតដោយស្ត្រីនៅខេត្តក្រចេះ ដោយច្រកក្នុងថង់ ផ្លាស្ទិចដែលមិនជ្រាបខ្យល់។

. **ការវេចខ្ចប់របស់ក្រុមហ៊ុនហ្វាមលីង (FARMLINK CO.,LTD) :** ខាងក្រុមហ៊ុនទិញតែប្រភេទស្ករម្សៅតែមួយមុខប៉ុណ្ណោះ រីឯការវេចខ្ចប់វិញ គឺមាន១ប្រភេទជាកញ្ចប់ដែលមានទម្ងន់៨០ក្រាម ដោយច្រកក្នុងថង់ប្លាស្ទិចដែលមិនជ្រាបខ្យល់។

. **ការវេចខ្ចប់របស់ក្រុមហ៊ុន SIGNATURES OF ASIAN CO.,LTD:** ខាងក្រុមហ៊ុនទិញតែប្រភេទស្ករម្សៅ តែមួយមុខប៉ុណ្ណោះ ហើយចំណែកឯការវេចខ្ចប់វិញគឺ មានមួយប្រភេទជាកញ្ចប់ដែលមានទម្ងន់ ០,៥ គីឡូក្រាម ដោយច្រកក្នុងថង់ប្លាស្ទិចដែលមិនជ្រាបខ្យល់។

ឧទាហរណ៍៖តួយ៉ាងការវេចខ្ចប់របស់ក្រុមហ៊ុនមានទំហំ ទម្ងន់ និងសោភ័ណភាពខុសៗគ្នា ៖




**រូបភាពទី 11 ៖ប្រភេទនៃការវេចខ្ចប់របស់ក្រុមហ៊ុន ខន់ហ្វីវ៉ែល**




**រូបភាពទី 12 ៖ប្រភេទនៃការវេចខ្ចប់របស់ក្រុមហ៊ុនសុវណ្ណៈ**

## ២.៤ ស្ថានភាពទីផ្សារ និងការចុះបញ្ជីស្ករត្នោតកំពង់ស្ពឺជាទំនិញសម្គាល់ភូមិសាស្ត្រ

### ២.៤.១ ការចុះបញ្ជីស្ករត្នោតកំពង់ស្ពឺជាទំនិញសម្គាល់ភូមិសាស្ត្រ

នៅឆ្នាំ២០១០ស្ករត្នោតកំពង់ស្ពឺត្រូវបានចុះបញ្ជីជាទំនិញសម្គាល់ភូមិសាស្ត្រតាមរយៈគម្រោងនាំមុខសម្រាប់ការពារផលិតផលសម្គាល់ភូមិសាស្ត្រនៅកម្ពុជា របស់ក្រសួងពាណិជ្ជកម្ម ដោយសហការណ៍ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ គម្រោងនេះ ទទួលបានមូលនិធិពីភ្នាក់ងារអភិវឌ្ឍន៍បារាំងសម្រាប់ការអភិវឌ្ឍន៍នៅកម្ពុជា (AFD) ជំនួយបច្ចេកទេសពីអង្គការហ្គ្រេត (GRET) និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា (CIRD) ដោយមានរយៈពេលពីរឆ្នាំកន្លះ ដោយគិតចាប់ពីខែ មិថុនា ឆ្នាំ២០០៧ ដល់ ខែធ្នូ ឆ្នាំ ២០០៩។ ហើយគោលបំណងសំខាន់នៃការចុះបញ្ជីនេះគឺដើម្បីការពារផលិតផលសម្គាល់ភូមិសាស្ត្ររបស់ផលិតករ ពាណិជ្ជករ និងអ្នកពាក់ព័ន្ធដទៃទៀត ក្រោមច្បាប់ការពារម៉ាកសញ្ញាសម្គាល់ភូមិសាស្ត្រទំនិញ ដើម្បីការពារទប់ស្កាត់ នឹងការក្លែងបន្លំសំដៅលើកកម្ពស់ និងកេរ្តិ៍ឈ្មោះ ផលិតផលពិតប្រាកដ ការពារអ្នកបរិភោគ និងបង្កើនប្រាក់ចំណូលដល់ផលិតករជនបទ។[22] លើសពីនេះទៀត សហភាពអឺរ៉ុបបានចេញផ្សាយស្ករត្នោតកំពង់ស្ពឺលើព្រឹត្តិបត្ររបស់ខ្លួន ដើម្បីរង់ចាំប្រតិកម្មឆ្លើយតបពីសមាជិក ហើយបើសិនជាមិនមានការជំទាស់ រឺការប្តឹងផ្តល់នោះទេ ស្ករត្នោតខេត្តកំពង់ស្ពឺ ក៏នឹងក្លាយជាផលិតផលកសិកម្មទី២របស់កម្ពុជាដែលនឹងទទួលស្គាល់ក្នុងទីផ្សារសហភាពអឺរ៉ុប ជាផលិតផលសម្គាល់ភូមិសាស្ត្រ GI នៅឆ្នាំ២០១៧ នេះ បន្ទាប់ពីម្រេចកំពតដែលបានទទួលស្គាល់នៅឆ្នាំ ២០១៦។ ដោយឡែក ស្ករត្នោតកំពង់ស្ពឺក៏ត្រូវបានទទួលស្គាល់ឋានៈជាផលិតផលសម្គាល់ភូមិសាស្ត្រ និងការពារពីប្រទេសថៃ និងវៀតណាម កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ ២០១៧ ថ្មីៗនេះផងដែរ។ ឋានៈ GI និងការទទួលស្គាល់ GI មកពីប្រទេសផ្សេងទៀតពិតជាមានសារៈសំខាន់ណាស់ ដោយសារតែ ឋានៈនេះនឹងជួយពង្រីកទីផ្សារថ្មី បន្ថែមតម្លៃផលិតផល បង្កើនទំនុកចិត្តសម្រាប់អតិថិជន និងជាពិសេសគឺបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារផលិតករស្ករត្នោត។[23]

### ២.៤.២ ស្ថានភាពទីផ្សារមុនពេលចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ

ស្ករត្នោត ត្រូវបានប្រជាពលរដ្ឋខ្មែរនិយមប្រើប្រាស់តាំងពីបុរាណកាលមក សម្រាប់ជាឱសថ និងគ្រឿងផ្សំម្ហូបអាហារ។ តែទោះជាយ៉ាងនេះក្តី មុនពេល ការបង្កើតសមាគម និងការចុះបញ្ជីជា

---

[22] បទសម្ភាសន៍ផ្ទាល់ជាមួយលោក សំ សារឿន ប្រធានសមាគមលើកកកម្ពស់ស្ករត្នោតកំពង់ស្ពឺ

[23] ចេង_សុខហ៊ង. ២០១៦. ការសែតភ្នំពេញប៉ុស្ត៍.

ទំនិញសម្គាល់ភូមិសាស្ត្រ ការផ្គត់ផ្គង់ស្ករត្នោតនៅលើទីផ្សារនៅមានកម្រិតទាបនៅឡើយ និង ហើយចំពោះ តម្លៃវិញគឺនៅមានកម្រិតទាប ពោលគឺត្រឹមតែ ១៣០០៛ ទៅ ១៧០០៛ ប៉ុណ្ណោះក្នុង មួយគីឡូក្រាម ស្របពេលដែលតំលៃស្ករស មានតម្លៃប្រហែល ១០០០៛ ក្នុងមួយគីឡូក្រាម។ ចំពោះទីផ្សារក្រៅប្រទេសវិញ ក៏មិនទាន់មានដែរនៅពេលនោះ ដោយសារតែស្ករត្នោតកំពង់ស្ពឺត្រូវ បានផលិតជា ២ ប្រភេទតែប៉ុណ្ណោះគឺ ស្ករសាច់ និងស្ករផែន ហើយស្ករទាំងនោះទៀតសោតក៏ ពុំទាន់ត្រូវបានត្រួតពិនិត្យ និងចេញវិញ្ញាបនបត្រទទួលស្គាល់គុណភាពពីភ្នាក់ងារត្រួតពិនិត្យគុណ ភាពអន្តរជាតិនៅឡើយទេ។

### ២.៤.៣ ស្ថានភាពទីផ្សារក្រោយពេលចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ

បន្ទាប់ពីស្ករត្នោតកំពង់ស្ពឺត្រូវបានចុះបញ្ជីជាផលិតផលសម្គាល់ភូមិសាស្ត្រតាមរយៈគម្រោង នាំមុខសម្រាប់ការពារទំនិញសម្គាល់ភូមិសាស្ត្រនៅកម្ពុជា របស់ក្រសួងពាណិជ្ជកម្មនៅឆ្នាំ ២០១០ មក ស្ករត្នោតកំពង់ស្ពឺត្រូវបានយកចិត្តទុកដាក់ ការពារ និងផ្សព្វផ្សាយបន្ថែមទៀត ពីអង្គភាពពាក់ ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលនានា។ ការធ្វើពិពិធកម្មផលិផលស្ករត្នោត មួយប្រភេទទៀត គឺស្ករ ម្សៅ ត្រូវបានធ្វើឡើង ក្រោមជំនួយបច្ចេកទេសពីអង្គការហ្គ្រេត (GRET) និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា (CIRD)។ តម្រូវការទីផ្សារ ក៏ត្រូវបានបង្កើនឡើងជាបន្តបន្ទាប់ ទាំងក្នុងស្រុក និងក្រៅស្រុក ដោយសារតែអតិថិជនដែលជាអ្នកប្រើប្រាស់ចុងក្រោយ ចាប់ផ្តើមទទួលស្គាល់និង ជឿជាក់លើគុណភាពផលិតផល។ ជាក់ស្តែងនៅឆ្នាំ ២០១០ ក្រុមហ៊ុន Confirel បាននាំចេញ ស្ករ ត្នោតចំនួន ១៧ តោន និង បន្តកើនឡើងដល់ ២៣ តោន នៅឆ្នាំ ២០១១ ទៅលក់នៅលើទីផ្សារ ក្រៅប្រទេស មានប្រទេសបារាំង ប្រទេសអូស្ត្រាលី ប្រទេសជប៉ុន និងកោះតៃវ៉ាន់។ នាពេល បច្ចុប្បន្ននេះ ស្ករត្នោតប្រភេទម្សៅ ដែលសហគមន៍ប្រមូលទិញផ្ទាល់ពី ផលិតករមានតម្លៃ ៥២០០៛ ក្នុងមួយគីឡូក្រាម និង លក់ទៅឲ្យក្រុមហ៊ុនវិញក្នុងតំលៃ ៦៥០០៛។ ក្នុងឆ្នាំ ២០១៦ ក្រុមហ៊ុនទាំង ៧ ដែលជាដៃគូ របស់សហគមន៍បាននាំចេញស្ករត្នោតទៅកាន់ប្រទេសចំនួន ២៦ ក្នុងបរិមាណ ប្រមាណ ១៥០ តោន។ហើយក្នុងឆ្នាំ ២០១៧ នេះវិញ ដោយសារតែក្រុមហ៊ុន Confirel កំពុងតែ សាងសង់ឃ្លាំងស្តុកថ្មី ជាហេតុនាំអោយមានតែក្រុមហ៊ុនចំនួន ៦ តែប៉ុណ្ណោះ ដែលបានបញ្ជាទិញ ស្ករត្នោតកំបង់ស្ពឺ ក្នុងបរិមាណសរុប ប្រហែល ៣០០ តោន ដែលភាគច្រើនជាស្ករត្នោតប្រភេទ ម្សៅ។ ប្រការនេះវាមិនត្រឹមតែជួយបង្កើនកេរ្តិ៍ឈ្មោះនិងតម្លៃដល់ស្ករត្នោតកំពង់ស្ពឺនៅលើទីផ្សារ ក្នុងស្រុក និងក្រៅស្រុកប៉ុណ្ណោះទេ ប្រាក់ចំណូល និងកម្រិតជីវភាព របស់ផលិតករស្ករត្នោតក៏ត្រូវ បានកើនឡើងជាមួយគ្នានោះដែរ។

## ២.៥ ប្រត្តិបត្តិការទីផ្សារស្ករត្នោតកំពង់ស្ពឺរបស់ ស.អ.ត.ក

### ២.៥.១ បណ្តាញទីផ្សារស្ករត្នោតកំពង់ស្ពឺ

សហគមន៍អភិវឌ្ឍន៍កសិកម្មត្នោតកំពង់ស្ពឺ ដើរតួជាឈ្មួញកណ្តាល ក្នុងការប្រមូលទិញស្ករពីសមាជិកនៃសមាគមលើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ ដើម្បីយកមក សម្ងួតបន្ថែម និងលក់បន្តទៅឲ្យក្រុមហ៊ុនជាដៃគូ ទៅតាមបរិមាណក្នុងកិច្ចសន្យា។ បន្ទាប់មកក្រុមហ៊ុនទាំងនោះ យកស្ករត្នោតទៅធ្វើការវេចខ្ចប់ជាកញ្ចប់តូចៗ តាមស្តង់ដាររបស់ក្រុមហ៊ុននីមួយៗ និងធ្វើការចែកចាយបន្តលើទីផ្សារគោលដៅរបស់ខ្លួន ទាំងក្នុងប្រទេស និងក្រៅប្រទេស។សម្រាប់ប្រភេទស្ករដែល ក្រុមហ៊ុនបញ្ជាទិញ មានតែ ៣ប្រភេទប៉ុណ្ណោះ គឺ ស្ករម្សៅ GI ស្ករម្សៅសរីរាង្គ និងស្ករសាច់។ នៅឆ្នាំ ២០១៧ ក្រុមហ៊ុនដែលបានទិញស្ករពី សហគមន៍មានចំនួន ៦ គឺ ក្រុមហ៊ុន SIGNATURE OF ASIA ក្រុមហ៊ុន កាតា ក្រុមហ៊ុន សុវណ្ណៈ ក្រុមហ៊ុន ហ្វាមលីង ក្រុមហ៊ុន តិបហ្គោ និងសហគ្រាសសេដាក។ ហើយក្រុមហ៊ុនទាំង ៦នេះ ភាគច្រើនបញ្ជាទិញស្ករម្សៅ GI ដោយក្នុងនោះមានតែសហគ្រាសសេដាក មួយប៉ុណ្ណោះ ដែលទទួលទិញបន្ថែមនូវ ស្ករសាច់ និងក្រុមហ៊ុន SIGNATURE OF ASIA ទទួលទិញស្ករម្សៅសរីរាង្គ។ ដោយឡែកក្រុមហ៊ុនដែលបានចុះកិច្ចសន្យាទិញ លក់ក្នុងបរិមាណជាក់លាក់នាដើមរដូវកាលផលិតកម្មជាមួយសហគមន៍មានតែចំនួន១ក្រុមហ៊ុនប៉ុណ្ណោះគឺក្រុមហ៊ុន SIGNATURE OF ASIA ហើយក្រុមហ៊ុននេះជាក្រុមហ៊ុនដែលបានបញ្ជាទិញស្ករត្នោតសំពង់ស្ពឺច្រើនជាងគេក្នុងឆ្នាំ ២០១៧ នេះ ។ចំណែកឯ ៥ ក្រុមហ៊ុនដ៏ទៃទៀត គឺបញ្ជាទិញទៅតាមតម្រូវការជាក់ស្តែង ជាបន្តបន្ទាប់នៅក្នុងរដូវកាលផលិតកម្ម។[24]

ក្រុមហ៊ុន SIGNATURE OF ASIA ក្រុមហ៊ុន កាតា ក្រុមហ៊ុន ហ្វាមលីង និងក្រុមហ៊ុនសុវណ្ណៈ ជាក្រុមហ៊ុនដែលធ្វើការនាំចេញស្ករត្នោតកំពង់ស្ពឺទៅលក់នៅក្រៅប្រទេស។ ក្នុងនោះការនាំចេញស្ករត្នោតមានចំនួន១៥ប្រទេស ជាទីផ្សារគោលដៅ រួមមាន បារាំង អូស្ត្រាលី អាល្លឺម៉ង់ អូទ្រីស ញូវហ្ស៊ីលែន ប៊ែលហ្ស៊ិក ហូឡង់ អាមេរិក ចិន ជប៉ុន កូរ៉េខាងត្បូង វៀតណាម និងម៉ាឡេស៊ី ជាដើម។

ចំពោះទីផ្សារក្នុងស្រុកវិញ គឺត្រូវបានផ្គត់ផ្គង់ ដោយក្រុមហ៊ុនចំនួន ៣ គឺ សហគ្រាស សេដាក ក្រុមហ៊ុន សុវណ្ណៈ និងក្រុមហ៊ុនតិបហ្គោ។ ក្រុមហ៊ុនទាំងបី បានចែកចាយស្ករត្នោតដែលបានវេចខ្ចប់រួចហើយ ទៅតាមទីផ្សារគោលដៅរបស់ខ្លួន ដែលមានដូចជា ផ្សារទំនើប ,ម៉ាត ភោជនីយដ្ឋាន និងហាងកាហ្វេ ក្នុងខេត្តសៀមរាប និងទីក្រុងភ្នំពេញ។

[24] បទសម្ភាសន៍ផ្ទាល់ជាមួយលោក សំ ផេង គណនេយ្យករនៃសហគមន៍លើកកម្ពស់កសិកម្មត្នោតកំពង់ស្ពឺ

## ២.៥.២ ទំហំនៃការធ្វើពាណិជ្ជកម្មស្ករត្នោតកំពង់ស្ពឺ

### ក. ទំហំពាណិជ្ជកម្មស្ករត្នោតកំពង់ស្ពឺរបស់ស.អ.ត.កតាមឆ្នាំនីមួយៗ

តម្រូវការស្ករត្នោតបានកើនឡើងឡើងពីមួយឆ្នាំ ទៅមួយឆ្នាំ។ ជាក់ស្តែងនៅឆ្នាំ ២០១៧ នេះ ក្រុមហ៊ុនជាដៃគូបានបញ្ជាទិញស្ករត្នោតសរុប ប្រមាណ ៣០០ តោន ពីសហាគមន៍ ដែលប្រៀបធៀបពីឆ្នាំ មុន គឺមានចំនួន ២៥០ តោន។ ប៉ុន្តែដោយសារអាកាសធាតុ ធ្វើអោយការផ្គត់ផ្គង់មិនគ្រប់តម្រូវការ ពោលគឺផ្គត់ផ្គង់បានតែជាង ១៤៦ តោនប៉ុណ្ណោះ ។តារាងខាងក្រោមនឹងបង្ហាញអំពីការផ្គត់ផ្គង់ស្ករត្នោតរបស់ សហគមន៍អភិវឌ្ឍន៍ស្ករត្នោតកំពង់ស្ពឺ តាមឆ្នាំនីមួយចាប់តាំងពី សហគមន៍នេះត្រូវបានបង្កើតឡើង។

**តារាងទី 6 ៖ ការផ្គត់ផ្គង់ស្ករត្នោតរបស់ ស.អ.ត.ក ចាប់តាំងពីឆ្នាំ ២០១១ (គិតជាតោន)**

| **ឆ្នាំ** | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|---|
| **បរិមាណស្ករ** | ០.៥ | ០.៥ | ១១ | ២៧ | ៤៧ | ១១៧ | ១៤៦ |

តាមតារាងខាងលើបានបង្ហាញអោយឃើញថា ការផ្គត់ផ្គង់ស្ករត្នោត របស់សហាគមន៍ ពី ឆ្នាំ ២០១១ ដល់ ២០១២ មានសភាពទាបខ្លាំងណាស់ពោលគឺ ត្រឹម ០.៥ តោន ប៉ុណ្ណោះ ដោយសារតែឆ្នាំនោះ ជាឆ្នាំ ដែលសហាគមន៍ទើបតែចាប់ផ្តើមដំណើរការប៉ុណ្ណោះ ហើយក៏មិនមានក្រុមហ៊ុនជាដៃគូរ ធ្វើការវេចខ្ចប់នាំចេញស្ករត្នោតទៅលក់នៅក្រៅប្រទេសដែរ ហើយតម្រូវការក្នុងស្រុកទៀតសោតក៏មិនសូវសំបូរ ដោយមានការប្រកួតប្រជែងខ្លាំង ជាមួយនឹងស្ករសនាំចូល និងស្ករត្នោតពីតំបន់ដ៏ទៃ។ ក្រោយមកបន្ទាប់ពីការខិតខំប្រឹងប្រែងក្នុងការផ្សព្វផ្សាយអំពី គុណភាព និងសារៈប្រយោជន៍ របស់ស្ករត្នោតកំពង់ស្ពឺ ពីសំណាក់ សមាគមអភិវឌ្ឍន៍ស្ករត្នោតកំពង់ស្ពឺ និងការទទួលបានវិញ្ញាបនបត្របញ្ជាក់អំពីគុណភាពនិងការទទួលស្គាល់ជាម៉ាកទំនិញសម្គាល់ភូមិសាស្រ្តជាអន្តរជាតិមក ក៏មានក្រុមហ៊ុនមួយចំនួន បានចាប់ផ្តើមមកចាប់ដៃគូរជាមួយនឹងសហាគមន៍ជាបន្តបន្ទាប់ ក្នុងការវេចខ្ចប់នាំចេញទៅលក់នៅក្រៅប្រទេស និងមួយចំនួនទៀតសម្រាប់ផ្គត់ផ្គង់តម្រូវការដែលមានស្រាប់នៅក្នុងស្រុក។ ជាក់ស្តែងនៅឆ្នាំ ២០១៣ ការផ្គត់ផ្គង់ស្ករត្នោតរបស់ ស.អ.ត.ក បានចំនួន ១១តោន និងបន្តកើនឡើងរហូតដល់ ១៤៦តោននៅឆ្នាំ ២០១៧។

**ក្រាបហ្វិកទី 1 ៖ក្រាបបង្ហាញពីការផ្គត់ផ្គង់ស្ករត្នោត (ស.អ.ត.) ចាប់តាំងពីឆ្នាំ ២០១១**




**ខ. ទំហំពាណិជ្ជកម្មស្ករត្នោតកំពង់ស្ពឺរវាងស.អ.ត.ក និងក្រុមហ៊ុនដៃគូរក្នុងឆ្នាំ ២០១៧**

ក្នុងឆ្នាំ ២០១៧នេះ មានក្រុមហ៊ុនជាដៃគូរ ចំនួន ៦ ក្រុមហ៊ុនបានធ្វើការបញ្ជាទិញស្ករត្នោតពីសហគមន៍។ ក្នុងនោះសហគមន៍បានធ្វើការផ្គត់ផ្គង់ស្ករត្នោតទៅឲ្យក្រុមហ៊ុននីមួយៗក្នុងបរិមាណដូចតារាងខាងក្រោម៖

**តារាងទី 7 ៖ ការផ្គត់ផ្គង់ស្ករត្នោតរបស់ស.អ.ត.កទៅឲ្យក្រុមហ៊ុននីមួយៗក្នុងឆ្នាំ២០១៧**

(គិតជាគ.ក្រ)

| ក្រុមហ៊ុន | ស្ករម្សៅ GI | ស្ករម្សៅសរីរាង្គ | ស្ករសាច់ GI | សរុប | ភាគរយ |
|---|---|---|---|---|---|
| កាតា | ២,១០០ | - | - | ២,១០០ | ១.៤ % |
| សេដាក | ៥៤០ | - | ១២០ | ៦៦០ | ០.៥ % |
| ហ្វាមលីង | ៣,០០០ | - | - | ៣,០០០ | ២.០ % |
| សុវណ្ណៈ | ២,៥០០ | - | - | ២,៥០០ | ១.៧ % |
| Signature | ១០៥,០០០ | ៣២,០០០ | - | ១៣៧,០០០ | ៩៣.៦ % |
| តិបហ្គោ | ១,១០០ | - | - | ១,១០០ | ០.៨ % |
| សរុប | ១១៤,២៤០ | ៣២,០០០ | ១២០ | ១៤៦,៣៦០ | ១០០.០ % |

**ក្រាបហ្វិកទី 2 ៖ក្រាបផ្ទិតបង្ហាញពីភាគរយនៃការផ្គត់ផ្គង់ស្ករត្នោតរបស់សហគមន៍ទៅតាមក្រុមហ៊ុននីមួយៗ**




### ២.៥.៣ ការកំណត់ថ្លៃទីផ្សារ

ជារៀងរាល់ខែតុលា ក្នុងឆ្នាំនីមួយៗ សមាគមលើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ តែងតែសម្របសម្រួលបង្កើតអោយមានការប្រជុំមួយ ដោយមានការចូលរួម ពី សហគមន៍អភិវឌ្ឍន៍កសិកម្មត្នោតកំពង់ស្ពឺ ដែលជាតំណាងផលិតករ និងក្រុមហ៊ុនជាដៃគូ ដើម្បីកំណត់ថ្លៃទីផ្សារនៃប្រភេទស្ករនីមួយៗ និងបរិមាណនៃតម្រូវការ និងការផ្គត់ផ្គង់ស្ករត្នោតកំពង់ស្ពឺសម្រាប់រដូវកាលផលិតកម្មបន្ទាប់។ ក្នុងនោះផងដែរតម្លៃស្ករត្នោត ត្រូវបានបង្កើនឡើងជារៀងរាល់ឆ្នាំ ទៅតាមចំណាយផលិតកម្មដែលបានកើនឡើង និងមួយវិញទៀតគឺដើម្បីលើកទឹកចិត្តដល់ប្រជាកសិករឲ្យបែរមកធ្វើផលិតកម្ម នេះកាន់តែច្រើនឡើង។

ជាក់ស្តែងនៅខែតុលា ឆ្នាំ ២០១៦ ឆ្លងតាមរយៈការប្រជុំ ទទួលបាននូវលទ្ធផលតម្លៃទីផ្សារ និងបរិមាណស្ករត្នោត សម្រាប់រដូវកាលផលិតកម្ម ឆ្នាំ២០១៧ ដូចខាងក្រោម ៖

- បរិមាណតម្រូវការស្ករត្នោត ដែលក្រុមហ៊ុនបានបញ្ជាទិញ សរុបប្រមាណ ៣០០ តោន។
- តម្លៃទិញ និងលក់ស្ករត្នោតតាមប្រភេទនីមួយៗដូចខាងក្រោម៖

**តារាងទី ៨ ៖ តំលៃទិញ-លក់ស្ករត្នោតក្នុងរដូវកាលផលិតកម្មឆ្នាំ ២០១៧**

| ប្រភេទស្ករ | ស្ករម្សៅ GI | ស្ករម្សៅសរីរាង្គ | ស្ករសាច់ |
|---|---|---|---|
| តំលៃ ស.អ.ត.ក ទិញពីផលិតករ | ៥,២០០ រ/គ.ក្រ | ៥,៨០០ រ/គ.ក្រ | ៤,០០០ រ/គ.ក្រ |
| តំលៃ ស.អ.ត.ក លក់អោយក្រុមហ៊ុន | ៦,០០០ រ/គ.ក្រ | ៧,២០០ រ/គ.ក្រ | ៤,៥០០ រ/គ.ក្រ |

## ២.៦. ការធ្វើអនាម័យ

ការធ្វើអនាម័យគឺជាការចាំបាច់ណាស់ សម្រាប់ផលិតករទូទៅក្នុងការប្រកបរបរនេះ បើពុំនោះទេស្ករនោះមិនអាចចាត់ចូលក្នុងស្កររបស់សហគមន៍លើកកម្ពស់ស្ករត្នោតកំពង់ស្ពឺឡើយ។ វិធីធ្វើអនាម័យមានដូចជា៖ នៅក្នុងដំណើរការនៃផលិតកម្ម«ស្ករត្នោតកំពង់ស្ពឺ» ផលិតករត្រូវធ្វើការសម្អាតដៃរបស់ខ្លួន ដោយលាងសម្អាតជាមួយនឹងសាប៊ូ។ ការសម្អាតដៃមាន៣ដំណាក់កាលគឺមុនពេលចាក់ទឹកត្នោតចូលខ្ទះ មុនពេលវិតស្ករ និងមុនពេលចាក់ស្ករត្នោតចូលក្នុងសម្ភារៈសម្រាប់ស្តុក ការលាងសម្អាតដៃ និងសាប៊ូឲ្យបានស្អាតមុនពេលរម្ងាស់ស្ករ អនាម័យទីកន្លែងផលិត ត្រូវបោសសម្អាតទីកន្លែងរម្ងាស់ស្ករត្នោតជាប្រចាំ ជាពិសេសគឺនៅមុនពេលកែច្នៃស្ករត្នោត។ អនាម័យសម្ភារៈប្រើប្រាស់ សម្រាប់ការប្រមូលផលទឹកត្នោត ត្រូវតែមានអនាម័យ ការកែច្នៃស្ករត្នោត ត្រូវតែសម្អាតអោយបានស្អាត ដោយលាងជាមួយទឹកត្រជាក់ និងទឹកក្តៅនៅក្រោយពេលប្រើប្រាស់រួច សម្រាប់ទុកដាក់ស្ករត្នោត ត្រូវតែជាសម្ភារៈដែលស្អាត។

## ២.៧ ការត្រួតពិនិត្យគុណភាព

តាមការចុះសិក្សា ការតាមដាន និងត្រួតពិនិត្យគុណភាពគឺចាំបាច់បំផុតដើម្បីធានាបាននូវកិត្តិសព្ទ និងការទទួលស្គាល់គុណភាពស្ករត្នោតកំពង់ស្ពឺជាផលិតផលសម្គាល់ភូមិសាស្ត្រដោយធ្វើឡើងមួយឆ្នាំម្តង។ ក្នុងការត្រួតពិនិត្យចែកចេញជា ៣ប្រភេទ ហើយប្រភេទទី១: ស្វ័យត្រួតពិនិត្យ ប្រភេទទី២: ការត្រួតពិនិត្យផ្ទៃក្នុង និងប្រភេទទី៣: ការត្រួតពិនិត្យខាងក្រៅ។ ចំពោះចំណុចដែលត្រួតពិនិត្យវិញមាន ២គឺការចុះបញ្ជីទទួលស្គាល់ផលិតករ និងការត្រួតពិនិត្យលើសៀវភៅបន្ទុក។

-**ស្វ័យត្រួតពិនិត្យ** : គឺជាការត្រួតពិនិត្យដោយផលិតករ និងប្រតិបត្តិករដែលត្រូវតែធ្វើការត្រួតពិនិត្យ និងប្រតិបត្តិតាមសៀវភៅបន្ទុក ដើម្បីអោយស្កររបស់ខ្លួនទទួលបាននូវគុណភាព និងការទទួលស្គាល់។

-**ការត្រួតពិនិត្យផ្ទៃក្នុង** : គឺជាការត្រួតពិនិត្យរបស់សមាគមទៅលើសមាជិករបស់ខ្លួនទាំងអស់គឺស្មើនិង ១០០ភាគរយ។

-**ការត្រួតពិនិត្យខាងក្រៅ** : គឺជាការត្រួតពិនិត្យពីខាងក្រៅដោយប្រព័ន្ធ ECOCERT SA របស់ប្រទេសបារាំងដោយធ្វើលើ សមាជិកចំនួនចាប់ពី ១០ ភាគរយ ទៅ ៣០ ភាគរយ និងផ្ទៀងផ្ទាត់តាមលទ្ធផលនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់សមាគម ចំនុចទាំងនោះរួមមានការត្រួតពិនិត្យលើបច្ចេកទេសនៃការប្រមូល ការរម្ងាស់ ការស្តុកទុក និងការវេចខ្ចប់ជាដើម។

## ២.៨ គណនេយ្យ និងការស្វែងរកទឹកដាន

យន្តការនៃការស្វែងរកទឹកដាន ត្រូវបានរៀបចំឡើង ដើម្បីធ្វើការតាមដានត្រួតពិនិត្យនូវរាល់បរិមាណសរុប និងដើម្បីកំណត់ថាតើផលិតផលមួយផលិតចេញពីទីកន្លែងណា។ រាល់ប្រតិបត្តិករដែលស្ថិតនៅក្នុងចង្វាក់ផលិតកម្មត្រូវតែរក្សាទុកនូវបញ្ជី ដើម្បីធ្វើការកត់ត្រាបរិមាណទឹកត្នោតដែលប្រមូលបាន លក់ ការទិញចូល ស្តុក បរិមាណស្ករត្នោតដែលផលិតបាន កាលបរិច្ឆេទនៃការ កែច្នៃ និងប្រភពស្ករត្នោត ហើយពួកគេត្រូវតែធ្វើការចុះបញ្ជី ដើម្បីទុកជាឯកសារយោងដែលត្រូវផ្តល់ជូនដល់អ្នកត្រួតពិនិត្យ និងដើម្បីប្រកាសពីទំនិញរបស់ខ្លួនក្នុងរយៈពេលមួយឆ្នាំ។

## ២.៩ ការដាក់ទណ្ឌកម្ម

តាមការសម្គាសផ្ទាល់ ប្រសិនបើផលិតករ និងប្រតិបត្តករមិនបានត្រឹមត្រូវតាមសៀវភៅបន្ទុកនោះពួកគាត់នឹងទទួលបានការព្រមានជាលាយលក្ខអក្សរ និងមិនអនុញ្ញាតឲ្យលក់នៅលើទីផ្សារដោយប្រើឈ្មោះស្ករត្នោតកំពង់ស្ពឺឡើយ។ អ្នកត្រួតពិនិត្យខាងក្រៅមានអំណាចក្នុងការសម្រេចចិត្ត និងអនុវត្តទណ្ឌកម្ម ប៉ុន្តែសមាគមអាចអនុវត្ត**ទណ្ឌកម្មកម្រិត១** ដោយណែនាំអប់រំទូន្មាន និង**ទណ្ឌកម្មកម្រិត២** ដោយការព្រមានហើយចាត់វិធានការជាបណ្តោះអាសន្នដោយដាក់**ទណ្ឌកម្មកម្រិត៣** ដោយទាត់ចោលឡូត៏ទាំងមូល ហើយចំពោះការរំលោភដ៏ធ្ងន់ធ្ងរ អាចនាំឲ្យមានការបណ្តេញប្រតិបត្តិករ ឬផលិតករពីសមាគម និងអាចដាក់ទោសដោយស្របទៅតាមច្បាប់ " ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ " របស់ប្រទេសកម្ពុជា ដែលបានអនុម័តនៅឆ្នាំ ២០១៤។

# ជំពូកទី ៣

# ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

## ៣.១ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃផលិតកម្មស្ករត្នោតកំពង់ស្ពឺក្នុងឃុំភ្នំតូច(១វដ្តផលិតកម្ម)

ដោយសារតែក្នុងឆ្នាំ ២០១៧ នេះស្ករសាច់ មិនសូវមានតម្រូវការទីផ្សារនោះទេ ហេតុនេះការវិភាគសេដ្ឋកិច្ចត្រូវបានតែធ្វើឡើងចំពោះតែប្រភេទស្ករម្សៅ GI តែប៉ុណ្ណោះ ដោយធ្វើការកំណត់យកសមាជិកផលិតករចំនួន ១៩ នាក់ ក្នុងឃុំ ភ្នំតូច មកធ្វើការវិភាគក្នុង ១ វដ្តផលិតកម្ម។

### ៣.១.១ ចំណាយសរុបជាមធ្យម របស់ផលិតករក្នុងការផលិតស្ករម្សៅ GI

ផ្អែកលើការអង្កេតដោយផ្ទាល់ ក្នុងដំណើរការផលិតកម្មស្ករត្នោតម្សៅ ការចំណាយរបស់ផលិតករនីមួយៗខុសគ្នាទៅតាម ចំនួនដើមត្នោត និងបរិមាណទឹកត្នោតដែលប្រមូលបាន។ ក្នុងនោះការចំណាយត្រូវបាន បែងចែកទៅលើមូលធនពីរគឺ ៖

- មូលធនថេរ រួមមាន ឡតដួ និងខ្នះត្នោតជាដើម ដែលការចំណាយលើមូលធននេះត្រូវបានគណនាតាមរំលោះនៃការប្រើប្រាស់ក្នុង ១ វដ្តផលិកម្ម ។
- មូលធនប្រែប្រួល រួមមាន អុស ស្បៃហ៊ុំ និង ខ្សែបង្ហោងជាដើម ដែលតម្លៃរបស់មូលធនប្រភេទនេះ ចូលរួមទាំងស្រុង ក្នុង១ វដ្តផលិតកម្ម។

**ក. ចំណាយថេរជាមធ្យម** (TFC)

ក្នុងដំណើរការផលិតកម្មស្ករម្សៅនេះ សមាជិកផលិករបានធ្វើការចំណាយលើមូលធនថេរដូចខាងក្រោម៖

**តារាងទី 9 ៖ ចំណាយថេរជាមធ្យមរបស់ផលិតករក្នុងការផលិតស្ករម្សៅ GI**

| ល.រ | មូលធនថេរ | ចំនួន | ឯកតា | តម្លៃ (៛/ឯកតា) | រយៈពេលប្រើប្រាស់ (វដ្តផលិតកម្ម) | តម្លៃរំលោះក្នុង ១ វដ្តផលិកម្ម |
|---|---|---|---|---|---|---|
| ១ | បំពង់ទឹកត្នោត | ១០៥ | រាយ | ១,២០០ | ២ | ៦៣,០០០ ៛ |
| ២ | កាំបិតត្នោត | ១ | រាយ | ៣៥,០០០ | ៣ | ១១,៧០០ ៛ |
| ៣ | ខ្នះត្នោត | ១ | រាយ | ២៤០,០០០ | ២ | ១២០,០០០ ៛ |
| ៤ | ឡតដួ | ១ | រាយ | ៩០០,០០០ | ៣ | ៣០០,០០០ ៛ |
| ៥ | ថាសដាក់ស្ករ | ១ | រាយ | ១៨,០០០ | ៣ | ៦,០០០ ៛ |

| | | | | | | |
|---|---|---|---|---|---|---|
| ៦ | ឆាកចូកស្ករ | ១ | រាយ | ១២,០០០ | ២ | ៦,០០០ ៛ |
| សរុប | | | | | | ៥០៦,៧០០ ៛ |

**ខ. ចំណាយប្រែប្រួលជាមធ្យម (TVC)**

សម្រាប់ចំណាយប្រែប្រួល ក្នុងដំណើរការផលិតកម្មស្ករម្សៅនេះ សមាជិកផលិករបានធ្វើការចំណាយលើមូលធនប្រែប្រួលដូចខាងក្រោម៖

**តារាងទី 10 ៖ ចំណាយប្រែប្រួលជាមធ្យមរបស់សមាជិកផលិតករក្នុងការផលិតស្ករម្សៅ GI**

| ល.រ | មូលធនប្រែប្រួល | ចំនួន | ឯកតា | តម្លៃ(៛/ឯកតា) | តម្លៃសរុប |
|---|---|---|---|---|---|
| ១ | ដើមត្នោត | ២១ | រាយ | ៥,២០០ ៛ | ១០៩,២០០ ៛ |
| ២ | ក្រម៉ាក្រវ៉ាត់ | ៣ | រាយ | ៨,០០០ ៛ | ២៤,០០០ ៛ |
| ៣ | ខ្សែបង្គោង | ១០ | រាយ | ៤,៥០០ ៛ | ៤៥,០០០ ៛ |
| ៤ | បង្គោងឬស្សី | ៤២ | រាយ | ១២,០០០ ៛ | ៥០៤,០០០ ៛ |
| ៥ | ខ្សែចងបំពង់ | ២ | រាយ | ១២,០០០ ៛ | ១៨,០០០ ៛ |
| ៦ | កញ្ជ្រែងច្រោះទឹកត្នោត | ១ | រាយ | ៥,០០០ ៛ | ៥,០០០ ៛ |
| ៧ | ស្បៃច្រោះទឹកត្នោត | ១ | គ.ក្រ | ៣,៥០០ ៛ | ៣,៥០០ ៛ |
| ៨ | រុក្ខជាតិពពេល | ៣០០ | គ.ក្រ | ១,៣០០ ៛ | ៣៩០,០០០ ៛ |
| ៩ | សាប៊ូ | ៦ | កញ្ចប់ | ៤,៥០០ ៛ | ២៧,០០០ ៛ |
| ១០ | អុស | ៣ | គោយន្ត | ២៣០,០០០ ៛ | ៦៩០,០០០ ៛ |
| ១១ | ស្បៃហ៊ុំ | ១០ | គ.ក្រ | ៣០,០០០ ៛ | ៣០០,០០០ ៛ |
| ១២ | កន្ត្រងច្រោះស្ករម្សៅ | ២ | រាយ | ៥,៥០០ ៛ | ១១,០០០ ៛ |
| សរុប | | | | | ២,០១៧,៥០០ ៛ |

**គ. ចំណាយសរុបជាមធ្យម (TC)**

តាមរូបមន្ត ៖

ចំណាយសរុប = ចំណាយថេរ + ចំណាយប្រែប្រួល

TC = TFC + TVC

តាមរូបមន្តខាងលើនាំអោយបាន តារាងដូចខាងក្រោម៖

| **ប្រភេទនៃចំណាយ** | **បរិមាណ (៛)** | **ភាគរយ** |
|---|---|---|
| ចំណាយថេរជាមធ្យម (TFC) | ៥០៦,៧០០ ៛ | ២០ % |
| ចំណាយប្រែប្រួលជាមធ្យម (TVC) | ២,០១៧,៥០០ ៛ | ៨០ % |
| ចំណាយសរុបជាមធ្យម (TC) | ២,៥២៤,២០០ ៛ | ១០០ % |

**តារាងទី 11 ៖ ចំណាយសរុបជាមធ្យម**

**ក្រាបផ្ទិតទី 3 ៖ក្រាបបង្ហាញពីភាគរយនៃការចំណាយរបស់ផលិតករ**



តាមលទ្ធផលវិភាគខាងលើបង្ហាញថា ការចំណាយរបស់ផលិតករ ទៅលើមូលធនថេរ គឺមានតិចជាង ចំណាយលើមូលធនប្រែប្រួល ពោលគឺ ចំណាយថេរជាមធ្យម មានប្រមាណ ៥០៦,៧០០៛ ដែលស្មើនឹង ២០% នៃចំណាយសរុប និងចំណាយប្រែប្រួលជាមធ្យម ចំនួន ២,០១៧,៥០០៛ ដែលស្មើនឹង ៨០%។

**៣.១.២ ចំណូលសរុបជាមធ្យម របស់ផលិតករក្នុងការផលិតស្ករត្នោតម្សៅ GI**

ចំណូលដែលផលិករនីមួយៗ ទទួលបានគឺខុសគ្នាអាស្រ័យទៅតាមចំនួនដើមត្នោត និងបរិមាណស្ករត្នោត ដែលផលិតបាន។ ក្នុងនោះផងដែរ តំលៃស្ករត្នោតត្រូវបានកំណត់ដូចគ្នា ជារៀងរាល់ដើមរដូវកាលផលិតកម្ម តាមរយៈ កិច្ចប្រជុំដែលមានការចូលរួមពីតំណាងផលិករ និងក្រុមហ៊ុនជាដៃគូក្រោមការសម្របសម្រួលរបស់សមាគមលើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ។ ជាក់ស្តែងក្នុងឆ្នាំ២០១៧ នេះតំលៃស្ករត្នោតមានតំលៃ៥២០០៛/គ.ក្រ។

តាមរូបមន្ត ៖

| |
|---|
| ចំណូល = តំលៃផលិតផលក្នុងមួយឯកតា * បរិមានផលិតផល |
| TR = P * Q |

ដែល តំលៃស្ករត្នោតម្សៅ GI ( P ) = ៥២០០៛/គ.ក្រ

